# ២.៥. ស្ថានភាពបច្ចុប្បន្ន និងនិន្នាការអភិវឌ្ឍន៍កំពង់ផែនៅតំបន់ទន្លេមេគង្គ

## ២.៥.១. កំពង់ផែភ្នំពេញ

### (១) លក្ខណៈទូទៅ

កំពង់ផែភ្នំពេញជាកំពង់ផែធំជាងគេទី ២ នៅកម្ពុជា។ បច្ចុប្បន្ន ឋបនីយភណ្ឌផែចិតនៅតាមច្រាំងទន្លេសាបភាគខាងលិចចំងាយ ២ គម ពីចំណុចប្រសព្វទន្លេចតុមុខនៃទន្លេមេគង្គ។ ផ្លូវចូលទៅកំពង់ផែនេះចាប់ពីច្រកសមុទ្រចិនខាងត្បូងកាត់តាមខេត្ត Cuu Tieu ប្រវែង ៣៣២ គម និងពីច្រកព្រំដែនកម្ពុជា-វៀតណាមក្អមសំណរប្រហែល ១០០ គម។

### (២) ការគ្រប់គ្រង និងប្រតិបត្តិការផែ

កំពង់ផែភ្នំពេញគ្រប់គ្រង និងធ្វើប្រតិបត្តិការដោយកំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.ព) ក្រោមការគ្រប់គ្រងរបស់ ស.ក.ដ.ជ និង ស.ហ.វ។ អង្គការលេខរបស់ ក.ស.ភ.ព មានបង្ហាញក្នុងរូប ២.៥-១។ ក.ស.ភ.ព គ្រប់គ្រងដោយអគ្គនាយក និងអគ្គនាយករង ៣ រូប និងប្រធាននាយកដ្ឋាន ៨ រូប។ នាយកដ្ឋានប្រតិបត្តិការចែកចេញជាពីរនាយកដ្ឋាន នៅពេលចំណតផែកុងតេន័រថ្មីចាប់ផ្តើមដំណើរការនៅឆ្នាំ ២០១២។




ប្រភព: ក.ស.ភ.ព

**រូប ២.៥-១: អង្គការលេខ ក.ស.ភ.ព**

ជាទូទៅ ក.ស.ភ.ព មានកម្មករខ្លួនឯងជាអ្នកលើកដាក់ទំនិញ ប៉ុន្តែសម្រាប់ដងយោងបណ្តែតរបស់ម្ចាស់សាឡង់គឺក្រុមហ៊ុនមានបុគ្គលិកខ្លួនឯងជាអ្នកបញ្ជាប្រតិបត្តិការ។

ផលិតភាពនៅពេលបច្ចុប្បន្នរបស់ដងយោងចល័ត និងដងយោងបណ្តែតលើកចុះបាន ១៥ ឯកតាក្នុងមួយម៉ោង និងលើកដាក់ចូលបាន ១០ ឯកតាក្នុងមួយម៉ោង។

តំបន់ពាណិជ្ជកម្មរបស់ ក.ស.ភ.ព គ្រប់ដណ្តប់លើតំបន់ដីសណ្តទន្លេមេគង្គប្រវែង ១៦០ គម ពីអ្នកលឿងដល់ខេត្តកំពង់ចាម។ ពេលមានភាគីទីបីណាមួយមានបំណងអភិវឌ្ឍន៍កំពង់ផែក្នុងតំបន់នេះ គេត្រូវពិភាក្សាពិគ្រោះយោបល់ជាមួយ ក.ស.

ភ.ព ជាមុនសិន។

**(៣) បរិក្ខារ និងគ្រឿងចក្រ**

កំពង់ផែភ្នំពេញមានចំណតផែបីដូចខាងក្រោម:-

- ចំណតផែកុងតេន័រ:
  ចំណត: 20m x 30m សមត្ថភាពចូលចតបាន: ម្តង ៣ សាឡង់
- កំពង់ផែក្នុងស្រុក:
  ប្រវែង ៣០០ម សម្រាប់បំរើសេវាកម្មនាវា/កាណូតដឹកជញ្ជូនឆ្លងខេត្ត
- ចំណតផែអ្នកដំណើរ:
  ផែបណ្តែត ២: មួយៗប្រវែង 15m x 45m

ក្រៅពីចំណតផែនៅតាមដងទន្លេខាងលើ ក.ស.ភ.ព មាន ICD មួយទំហំ ៩២.០០០ម$^{២}$។ ដោយទីលានផែនៅតាមដងទន្លេមានទំហំតូចចង្អៀត ក.ស.ភ.ព ក៏ជំរុញឱ្យប្រើប្រាស់ ICD វិញ។

បូមស្តារផែទាំប្រឡាយនាវាចរណ៍ក្អមសំណរ-ភ្នំពេញ និង ភ្នំពេញ-កំពង់ចាមធ្វើជារៀងរាល់ឆ្នាំ គឺរយៈពេល ២ ឬ ៣ ខែនៅដូវប្រាំង ដោយនាវាបូមស្តារ និងបុគ្គលិករបស់ ក.ស.ភ.ព ខ្លួនឯង។ បរិមាណបូមស្តារប្រចាំឆ្នាំប្រមាណ ១០០.០០០ម$^{៣}$។ ពេលខ្លះកប៉ាល់បូមស្តាររបស់ ក.ស.ភ.ព ត្រូវក្រុមហ៊ុនជួលឱ្យទៅបូមរានដីផងដែរ...។ល។




រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៩-២: ទីតាំងចំណតផែកុងតេន័រនៅកំពង់ផែភ្នំពេញ**

### (៤) ផ្លូវថ្នល់ និងផ្លូវរថភ្លើងចូលទៅផែ

កំពង់ផែនៅជាប់ផ្លូវជាតិលេខ ៥ ដែលកំណាត់ផ្លូវនេះថិតនៅទីប្រជុំជនទីក្រុងភ្នំពេញមានលក្ខណៈតូចចង្អៀត។ ដូចនេះ កំពង់ផែបានប្រើប្រព័ន្ធគ្រប់គ្រងចរាចរដោយកាមេរ៉ាសុវត្ថិភាព CCTV ដើម្បីកាត់បន្ថយការកកស្ទះចរាចរដូចមានពិពណ៌នាក្នុងចំណុច ២.៤.១។

ផ្លូវថេភ្លើងចូលទៅផែបច្ចុប្បន្នពុំទាន់មាននៅឡើយ។ ក.ស.ភ.ព គ្រោងសាងសង់ចំណតផែពហុវិស័យ (intermodal terminal) តភ្ជាប់ការដឹកជញ្ជូនតាមរថភ្លើង/ផ្លូវថ្នល់ ជាមួយការដឹកជញ្ជូនតាមផ្លូវទឹកនៅកំពង់ផែគីឡូម៉ែត្រលេខ ៦ ចំងាយ ៦ គម ពីចំណុចប្រសព្វទន្លេបចតុមុខ និង ៤ គម ពីកំពង់ផែមេ។

### (៥) ចរាចរទំនិញ/អ្នកដំណើរ និង ចំនួននាវាចេញចូលផែ

តារាង ២.៥-១ បង្ហាញពីចំនួននាវាចេញចូលផែតាមលំដាប់ពេលនៅកំពង់ផែភ្នំពេញ។ នៅរយៈពេល ១០ ឆ្នាំ កន្លងមក ចំនួននាវាចេញចូលផែមានការផ្លាស់ប្តូរតិចតួច។ ចាប់តាំងពីឆ្នាំ ២០០៣ មក សាឡង់ក្នុងស្រុកចូលមកកំពង់ផែនេះកាន់តែតិចទៅៗ ហើយគ្មានទាំងស្រុងនៅឆ្នាំ ២០០៧។ ទន្ទឹមគ្នានោះ សាឡង់/នាវាអន្តរជាតិចេញចូលផែនេះមានកាន់តែច្រើន តែចំនួននេះបើធៀបទៅនឹងកំនើនបរិមាណទំនិញឆ្លងកាត់ផែគឺមិនស៊ូវជាច្រើនប៉ុន្មានទេ ដោយទំហំនាវាគេពង្រីកកាន់តែធំទៅៗ។

**តារាង ២.៥-១: ចំនួននាវាចេញចូលផែភ្នំពេញ**

| Year | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|---|
| International Vessel/Barge | 209 | 107 | 87 | 109 | 210 | 254 | 377 | 484 | 387 | 318 |
| Oil Vessel | 573 | 522 | 592 | 639 | 708 | 831 | 894 | 951 | 1,026 | 657 |
| DomesticVessel | 38 | 21 | 89 | 124 | 158 | 147 | 125 | 108 | 107 | 82 |
| Domestic Barge | 257 | 281 | 305 | 222 | 110 | 32 | 2 | 0 | 0 | 0 |
| TOTAL | 1,077 | 931 | 1,073 | 1,094 | 1,186 | 1,264 | 1,398 | 1,543 | 1,520 | 1,057 |

ប្រភព: ក.ស.ភ.ព

ដូចដែលបានបង្ហាញក្នុងតារាង ២.៥-២ ទំនិញនាំចូលឆ្លងកាត់កំពង់ផែនេះភាគច្រើនគឺទំនិញចាក់ធាររាវ (ផលិតផលប្រេងនាំចូលពីវៀតណាម) ប្រមាណជាង ៦០% នៃទំនិញឆ្លងកាត់ផែសរុប និងស្មើរ ៧០% នៃទំនិញនាំចូល។ ទំនិញឆ្លងកាត់ផែភ្នំពេញមានការកើនឡើងលឿនស្របជាមួយការអភិវឌ្ឍន៍រាជធានី និងកំនើនឧស្សាហកម្មរបស់ប្រទេសនេះ។ ពិសេសកំនើនគួរឱ្យកត់សំគាល់គឺចរាចរកុងតេន័។ ដូចមានបង្ហាញក្នុងតារាង ២.៥-៣ កំពង់ផែនេះគេប្រើសំខាន់សម្រាប់ការនាំចូល តែចាប់តាំងពីឆ្នាំ ២០០៩ មក កុងតេន័រនាំចេញក៏បានកើនឡើង ហើយនៅឆ្នាំ ២០១០ កំពង់ផែលើកដាក់កុងតេន័រនាំចេញច្រើនជាងកុងតេន័រនាំចូល។ នេះដោយសារមានការនាំចេញកុងតេន័រសំលៀកបំពាក់ទៅសហរដ្ឋអាមេរិចខ្លះប្តូរពីកំពង់ផែក្រុងព្រះសីហនុមកកំពង់ផែភ្នំពេញវិញ ព្រោះកំពង់ផែខាយម៉ែបបានចាប់ផ្តើមដំណើរការ និងមានកំនើននាំចេញអង្ករ។

**តារាង ២.៥-២: បរិមាណទំនិញឆ្លងកាត់កំពង់ផែភ្នំពេញ**

(tons)

| Year | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|---|
| Imported Cargo | 462,471 | 403,870 | 495,295 | 557,634 | 678,159 | 880,126 | 1,020,391 | 1,168,556 | 1,192,429 | 1,100,227 |
| General Cargo | 61,267 | 32,893 | 29,217 | 22,561 | 41,031 | 3,845 | 50,695 | 105,485 | 96,600 | 67,324 |
| Containers | 154 | 2,202 | 46,802 | 74,421 | 172,762 | 229,956 | 265,195 | 283,035 | 227,887 | 255,035 |
| Liquid Bulk | 401,050 | 368,775 | 419,276 | 460,652 | 464,366 | 646,325 | 704,501 | 780,036 | 867,942 | 777,868 |
| Exported Cargo | 33,646 | 12,117 | 24,589 | 23,867 | 31,964 | 52,465 | 44,894 | 42,971 | 79,458 | 159,029 |
| General Cargo | 33,646 | 10,370 | 1,122 | | 225 | 600 | | | 671 | 7,628 |
| Containers | | 1,747 | 23,467 | 23,867 | 31,739 | 51,865 | 44,894 | 42,971 | 78,787 | 151,401 |
| TOTAL | 496,117 | 415,987 | 519,884 | 581,501 | 710,123 | 932,591 | 1,065,285 | 1,211,527 | 1,271,887 | 1,259,256 |

ប្រភព: ក.ស.ភ.ព

**តារាង ២.៥-៣: បរិមាណកុងតេន័រឆ្លងកាត់កំពង់ផែភ្នំពេញ**

(TEUs)

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|
| Import | | | | | | | | | |
| Empty | 100 | 306 | 985 | 867 | 477 | 1,126 | 1,387 | 3,769 | 5,940 |
| Laden | 242 | 4,134 | 7,054 | 14,077 | 18,099 | 23,783 | 23,623 | 16,735 | 21,369 |
| Export | | | | | | | | | |
| Empty | 167 | 1,118 | 4,250 | 11,570 | 14,316 | 16,653 | 16,754 | 11,033 | 10,671 |
| Laden | 237 | 2,072 | 3,237 | 3,767 | 5,341 | 5,942 | 5,743 | 11,775 | 24,276 |
| Total Throughput | 746 | 7,630 | 15,526 | 30,281 | 38,233 | 47,504 | 47,507 | 43,312 | 62,256 |

ប្រភព: ក.ស.ភ.ព

តារាង ២.៥-៤ បង្ហាញពីចរាចរអ្នកដំណើរនៅកំពង់ផែភ្នំពេញ។ ចំនួនអ្នកដំណើរសរុបបានធ្លាក់ចុះ ដោយសារការដឹកជញ្ជូនតាមកាណូត/កប៉ាល់ឆ្លងកាត់ខេត្តផ្សេងៗមានការថយចុះ ព្រោះបណ្តាញផ្លូវថ្នល់ត្រូវបានកែលំអរ។ ទោះយ៉ាងណា គេសង្កេតឃើញថានៅមាននិន្នាការកើនឡើង ដោយសារកំនើនអ្នកដំណើរអន្តរជាតិ និងភ្ញៀវទេសចរណ៍។

**តារាង ២.៥-៤: ចរាចរអ្នកដំណើរនៅកំពង់ផែភ្នំពេញ**

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|
| Inter-provincial Ferry | 184,420 | 110,115 | 58,949 | 34,722 | 35,463 | 36,277 | 28,674 | 20,019 | 18,527 |
| Ferry to Chau Doc (VN) | 3,789 | 3,847 | 5,943 | 6,173 | 9,235 | 12,862 | 14,803 | 12,860 | 15,618 |
| Tourist in Town | 7,205 | 2,386 | 2,663 | 820 | 746 | 1,013 | 350 | 866 | 5,231 |
| Tour to Viet Nam | | 466 | 1,985 | 2,812 | 2,156 | 3,065 | 3,083 | 4,390 | 9,738 |
| TOTAL | 195,414 | 116,814 | 69,540 | 44,527 | 47,600 | 53,217 | 46,910 | 38,135 | 49,114 |

ប្រភព: ក.ស.ភ.ព

### (៦) ផែនការអភិវឌ្ឍន៍

ឆ្លើយតបទៅនឹងកំនើនចរាចរកុងតេន័រយ៉ាងឆាប់រហ័សក.ស.ភ.ព កំពុងអភិវឌ្ឍន៍ចំណតផែកុងតេន័រថ្មីមួយទៀតនៅស្រុកកៀនស្វាយ ខេត្តកណ្តាល ចំងាយ ៣០ គម ខាងកើតទីក្រុងភ្នំពេញ នៅតាមដងទន្លេមេគង្គ និងផ្លូវជាតិលេខ ១។ គម្រោងអភិវឌ្ឍន៍កំពុងអនុវត្តបីដំណាក់កាល។

សមត្ថភាពលើកដាក់បានក្នុងមួយឆ្នាំនៅចំណតផែថ្មីនោះគឺ ៥០០.០០០TEU។ ការអភិវឌ្ឍន៍ដំណាក់កាលទី ១ នឹងត្រូវបញ្ចប់នៅខែ មិថុនា ឆ្នាំ ២០១២ ចំណតផែមានសមត្ថភាពលើកដាក់បាន ១២០.០០០ TEU មានចំណតប្រវែង ៣០០ ម លើផ្ទៃដីផែទំហំ ២០ ហត។ នៅចំណតផែថ្មីនេះ នាវាចំណុះរហូតដល់ ៥.០០០ DWT អាចចូលចតបាន។ ការអភិវឌ្ឍន៍ដំណាក់កាលទី ២ សមត្ថភាពលើកដាក់បាននឹងកើន ១៨០.០០០ TEU ដូចនេះសមត្ថភាពលើកដាក់បានសរុបនឹងកើនទៅដល់ ៣០០.០០០ TEU។ ការសិក្សាលំអិតពីគម្រោងអភិវឌ្ឍន៍ដំណាក់កាលទីពីរនឹងទីបីធ្វើឡើង ក្រោយពីចាប់ផ្តើមដំណើរការចំណតផែដែលបានអភិវឌ្ឍន៍នៅដំណាក់កាលទី ១។ ដីសម្រាប់ការអភិវឌ្ឍន៍នៅដំណាក់កាលទី ២ និងទី ៣ ក.ស.ភ.ព ត្រៀមរួចរាល់អស់ហើយ ចំណែការងាររានដីនៅតំបន់នេះកំពុងតែធ្វើជាបណ្តើរៗហើយដែរ។ ដីត្រូវការសម្រាប់គម្រោងអភិវឌ្ឍន៍នេះនៅតាមដងទន្លេប្រវែង ១.៥០០ ម៉ែត្រ។ ក.ស.ភ.ព បានព្យាការណ៍ថាកុងតេន័រលើកដាក់បាននឹងមានចំនួនកើនឡើងរហូតដល់ ៣០០.០០០ TEU មុនឆ្នាំ ២០២០ ដូចនេះគេត្រូវបញ្ចប់គម្រោងអភិវឌ្ឍន៍ដំណាក់កាលទី ២ ឱ្យបានឆ្នាំនេះ។

គម្រោងអភិវឌ្ឍន៍ដំណាក់កាលទី ១ ផ្តល់ហិរញ្ញប្បទានដោយកម្ចីការប្រាក់ទាបពីរដ្ឋាភិបាលចិន។ គម្រោងកម្ចីការប្រាក់ទាបរបស់ចិនគឺសម្រាប់តែសាងសង់ហេដ្ឋារចនាសម្ពន្ធ័ និងអាគារការិយាល័យប៉ុណ្ណោះ។ គេគ្រោងដាក់ដងយោងនៅច្រាំងចំណត និង RTGs នៅចំណតផែកុងតេន័រថ្មីនេះ ដែលទីភ្នាក់ងារសាធារណៈកម្ពុជា ដូចជាកំាសាប ជាអ្នកផ្តល់ហិរញ្ញប្បទាន។ ការដាក់ដែករ៉ៃសម្រាប់ដងយោងធុនធ្ងន់ក៏រាប់បញ្ចូលក្នុងកម្ចីការប្រាក់ទាបរបស់ចិននេះដែរ តែមិនទាន់សម្រេចនៅឡើយថាតើ ក.ស.ភ.ព ត្រូវទិញដងយោងធុនធ្ងន់ ឬ ដងយោងចល័តនៅកំពង់ផែ។ ការអភិវឌ្ឍន៍ដំណាក់កាលទី ២ គ្រោងនឹងបញ្ចប់ដោយគម្រោងថវិការបស់ ក.ស.ភ.ព ខ្លួនឯង ចំណែកមូលនិធិពីខាងក្រៅ គេរំពឹងនឹងទុកប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍ដំ

ណាក់កាលទី ៣។

អាគាររដ្ឋបាលថ្មីនៅចំណតផែកុងតេន័រថ្មីទុកសម្រាប់តែថ្នាក់គ្រប់គ្រងធ្វើការ។ ទីស្នាក់ការធំរបស់ ក.ស.ភ.ព រក្សានៅទីតាំងចាស់ដដែលគឺនៅកំពង់ផែភ្នំពេញបច្ចុប្បន្ន។

ផ្លូវកាត់ថ្មីមួយតភ្ជាប់ផ្ទាល់ពីចំណតផែថ្មីនេះទៅផ្លូវជាតិលេខ ៣ និង លេខ ៤ កំពុងតែសាងសង់ ចំណែកផ្លូវរថភ្លើងមិនទាន់មានគម្រោងសាងសង់នៅឡើយ។

យោងទៅតាមការពន្យល់បកស្រាយពី ក.ស.ភ.ព ចំណតផែថ្មីនេះនឹងត្រូវកាន់កាប់គ្រប់គ្រងធ្វើប្រតិបត្តិការផ្ទាល់ដោយ ក.ស.ភ.ព ខ្លួនឯង។




រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៩.៣ ទីតាំងកំពង់ផែភ្នំពេញថ្មី**




ប្រភព: ក.ស.ភ.ព

**រូប ២.៩-២: គម្រោងអភិវឌ្ឍន៍កំពង់ផែភ្នំពេញថ្មី (ដំណាក់កាលទី ១)**



រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-៥: កំពង់ផែភ្នំពេញថ្មី (កំពុងសាងសង់ (ខែ កុម្ភៈ ឆ្នាំ ២០១២))**



រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-៦: ដីវានសម្រាប់អភិវឌ្ឍន៍ដំណាក់កាលទី ៣ នៃកំពង់ផែភ្នំពេញថ្មី**

### ២.៥.២. កំពង់ផែនៅតាមខេត្ត និងកំពង់ផែឯកជននៅកម្ពុជា

#### (១) កំពង់ផែនៅតាមខេត្ត

នៅកម្ពុជាមានកំពង់ផែសមុទ្រតាមខេត្តប្រាំដូចជាៈ-កំពង់ផែកោះកុង កំពង់ផែស្ទឹងត្រែង កំពង់ផែទំនប់រលក កំពង់ផែកំពត និងកំពង់ផែកែប។ ជាទូទៅ កំពង់ផែសមុទ្រនៅតាមខេត្តមានទំហំតូច ពុំមានវាបនីយភណ្ឌផែត្រឹមត្រូវ ឬ គ្រប់គ្រាន់ទេ មានត្រឹមតែចំណតផែធ្វើពីឈើ ទីលានផែដីធម្មតាមិនមានចាក់សាប គ្មានគ្រឿងចក្រលើកដាក់ទំនើបៗអ្វីនោះទេ។ កំពង់ផែទាំងនេះគេប្រើសំខាន់សម្រាប់ការដឹកជញ្ជូនតាមផ្លូវសមុទ្រមកពីឆ្នេរភាគខាងកើតប្រទេសថៃ។

កំពង់ផែទំនប់រលកឋិតនៅក្នុងតំបន់ជលសីមា (ទំនប់ការពារទឹករលក) របស់កំពង់ផែក្រុងព្រះសីហនុដូចមានបង្ហាញក្នុង រូប ២.៥-៧ ជាកន្លែងគេគ្រោងរានដីដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម ទៅតាមផែនការមេដំបូងរបស់កំពង់ផែក្រុងព្រះសីហនុ។ រដ្ឋជាអ្នកសាងសង់កំពង់ផែនេះនៅឆ្នាំ ១៩៨៩ (នោះគឺមន្ទីសាធារណការ និងដឹកជញ្ជូន និងសាលាខេត្តព្រះសីហនុ)។ ទីលានកំពង់ផែជាដីធម្មតាមិនមានការចាក់សាបទំហំ ៧០០ ម² មានឃ្លាំងទុកទំនិញមួយ (ទំហំ ១៦១ ម²) និងដងយោងមួយ (២៥ តោន)។ ជំរៅទឹកបច្ចុប្បន្ននៅកំពង់ផែនេះមានកំពស់ ៤ ម ទៅ ៦ ម។ នៅពេលទឹកនាច ជំរៅទឹកនៅសល់ត្រឹម ២.៨ ម ទៅ ៣.៩ ម និងនៅពេលទឹកជោរ កំពស់ទឹកឡើងទៅដល់ ៥ ម និង ៦ ម។ កំពង់ផែនេះគឺជារបស់រដ្ឋឋិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីសាធារណការ និងដឹកជញ្ជូនរហូតដល់ឆ្នាំ ១៩៩៥។ ចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦ មន្ទីសាធារណការ និងដឹកជញ្ជូនបានប្រែក្លាយការគ្រប់គ្រងកំពង់ផែនេះទៅឋិតក្រោមការគ្រប់គ្រងឯកជនវិញតាមរយៈការដាក់ដេញថ្លៃ។ ទំនិញឆ្លងកាត់កំពង់ផែនេះមានដូចជាៈ-ទំនិញប្រើប្រាស់ធម្មតា និងគ្រឿងសំណង់ នាំចូលពីប្រទេសថៃតាមសាឡង់ ឬ កប៉ាល់ឈើ។ នៅរយៈពេល ៦ ខែ ពីខែ តុលា ឆ្នាំ ២០១០ កំពង់ផែនេះលើកដាក់ទំនិញបាន ៨០.០០០ តោន។ ទំនិញលើកដាក់នៅកំពង់ផែនេះទាំងអស់សុទ្ធសឹងជាទំនិញនាំចូល។ នៅរយៈពេលដូចគ្នា មាននាវាចូលផែចំនួន ១៣៦ គ្រឿង។

កំពង់ផែកំពតឋិតនៅច្រាំងខាងលិចព្រែកកំពត ចំងាយ ១២ គម ពីលំហរសមុទ្រ បើទោះកំពង់ផែនេះត្រូវគេចាត់ទុកជាកំពង់ផែសមុទ្រក៏ដោយ។ កំពង់ផែនេះសាងសង់ឡើងនៅឆ្នាំ ១៩២២ បន្ទាប់មកបានក្លាយជាកំពង់ផែសមុទ្រសំខាន់មួយឋិតក្នុងទឹកដីកម្ពុជារហូតដល់កំពង់ផែក្រុងព្រះសីហនុបើកដំណើរការ។ វាជាកំពង់ផែតូច មានវាបនីយភណ្ឌផែបន្សល់ទុកតាំងពីយូរលង់ណាស់មកហើយសម្រាប់ឱ្យទូកធ្វើពីឈើតូចៗ និងសាឡង់តូចៗចូលចត មិនមានគ្រឿងចក្រលើកដាក់ទំនិញអ្វីទេ។ ប្រឡាយទឹកចូលផែពីដើមមកមានជំរៅ ៥.៥ ម តែបច្ចុប្បន្នមានជំរៅពី ១.៥ ម ទៅ ៣.៥ ម។ ពីមុនមក កំពង់ផែនេះជារបស់រដ្ឋតែនៅ

ឆ្នាំ ១៩៩៥ មន្ទីសាធារណការ និងដឹកជញ្ជូនខេត្ត បានដាក់ដេញថ្លៃឱ្យក្រុមហ៊ុនឯកជនគ្រប់គ្រងវិញ តែថិតក្រោមការគ្រប់គ្រងបច្ចេកទេសរបស់មន្ទីសាធារណការ និងដឹកជញ្ជូនខេត្តកំពត។ ទំនិញដឹកជញ្ជូនឆ្លងកាត់កំពង់ផែនេះមានដូចជា:-ស្ករស ដ្ឋ គ្រឿង ហ្វីប្រូ របាដែក ។ល។ ភាគច្រើននាំចូលពីប្រទេសថៃ និងតិចតួចមកពីវៀតណាម។ ស្ករសនាំចូលពីថៃត្រូវផ្ទេរនៅកំពង់ផែនេះ និងដឹកបន្តនាំចេញទៅវៀតណាម។ ទំនិញនាំចូលពីថៃមានប្រមាណ ២០.០០០ តោន ក្នុងមួយឆ្នាំ។ ទំនិញមកពីថៃគឺដឹកតាមកប៉ាល់ឈើ ឬ សាឡង់ចំណុះ ៥០០ តោន ទៅ ១.០០០ តោន ហើយផ្ទេរទៅកប៉ាល់ឈើ ៥០ តោន ដឹកតាមឆ្នេរសមុទ្រខេត្តកំពត។

ក្រុមហ៊ុនអភិវឌ្ឍន៍ SEZ ឯកជនមានគម្រោងសាងសង់កំពង់ផែទឹកជ្រៅនៅតាមឆ្នេរសមុត្រខេត្តកំពត។ នៅពេលកន្លងមក គេប្រកាសថាកំពង់ផែថ្មី និង SEZ នឹងត្រូវបញ្ចប់នៅឆ្នាំ ២០១០ តែតាមការស៊ើបអង្កេតរបស់ក្រុមសិក្សាគម្រោងគឺនៅខែ កក្កដា ឆ្នាំ ២០១១ មានតែទប់ច្រាំងរានដីសាងសង់ SEZ ប៉ុណ្ណោះ។ ឋបនីយភណ្ឌចំណតមិនទាន់ចាប់ផ្តើមសាងសង់នៅឡើយទេ។

កំពង់ផែស្ទឹងហាវថិតនៅច្រាំងសមុទ្រភាគខាងត្បូងនៃខេត្តព្រះសីហនុ ចំងាយប្រហែល ២០ គម ពីកំពង់ផែក្រុងព្រះសីហនុ និង ៣០ គម ពីវាលរិញ នៅផ្លូវជាតិលេខ ៣ និង លេខ ៤។ បច្ចុប្បន្ន ក្រៅពីផលិតផលប្រេងបូមនៅផែប្រេង មានទំនិញតិចតួចណាស់លើកដាក់នៅកំពង់ផែស្ទឹងហាវនេះ។ ពីដើមមក កំពង់ផែនេះគេប្រើធ្វើជាកំពង់ផែនេសាទ។ ក្រុមហ៊ុន Attwood Investment Group មានគម្រោងធ្វើ SEZ មានកំពង់ផែកុងតេន័រនៅទីតាំងដែលមានឋបនីយភណ្ឌផែស្រាប់។ ដីគ្រោងសាងសង់ SEZ និងកំពង់ផែមានទំហំ ៥២០ ហត ក្នុងនោះ ៤០០ ហត ជាបាសាំងការពារដោយជលសីមាប្រវែងជាង ៧.៦ គម ដូចមានបង្ហាញក្នុងរូប ២.៥-១០។ ជំរៅទឹកអតិបរមានៅតាមច្រាំងចំណតដែលគ្រោងនឹងធ្វើគឺ ១២ ម។ ការងារបូមស្តារធ្វើបាសាំង និងប្រឡាយទឹកចូលផែ (ករណីប្រឡាយទឹកប្រវែង ៣.៧ គម ទទឹង ៣០០ ម) តាមការប៉ាន់ស្មានប្រមាណ ២១ លាន ម$^{៣}$។ ពិធីបើកសម្ពោធន៏សាងសង់បានធ្វើនៅឆ្នាំ ២០០៩។ គម្រោងអភិវឌ្ឍន៍នេះមានបួនដំណាក់កាល។ ដំណាក់កាលទី ១ សាងសង់ឋបនីយភណ្ឌផែគ្រោងនឹងបញ្ចប់រយៈពេលពីរ ឬ បីឆ្នាំ ក្រោយពីចាប់ផ្តើមគម្រោង។ ទោះយ៉ាងណា ឋបនីយភណ្ឌផែនៅកំពុងសាងសង់ នៅពេលក្រុមសិក្សាគម្រោងបានចុះអង្កេតជាក់ស្តែងដល់កន្លែងនៅខែ កក្កដា ឆ្នាំ ២០១១។ ឋបនីយភណ្ឌផែសាងសង់នៅដំណាក់កាលទី ១ ទំនងធ្វើទៅតាមគម្រោងប្លង់ដឹកជញ្ជូនបែបប្រពៃណីយ៍ ដែលវាមិនបង្ករលក្ខណៈងាយស្រួលដល់រោងចក្រ SEZ នោះទេ។ ផ្លូវថ្នល់ថ្មីពីស្ទឹងហាវទៅផ្លូវជាតិលេខ ៤ បានបើកឱ្យប្រើប្រាស់នៅខែ មេសា ឆ្នាំ ២០០៧។

កំពង់ផែកោះកុងថិតនៅមុខទីរួមខេត្តកោះកុង មុនឆ្លងស្ពានទៅ SEZ កោះកុង និងប៉ុស្តិ៍ត្រួតពិនិត្យនៅច្រកព្រំដែន។ ចំណតផែប្រវែង ៥០ ម សម្រាប់លើកដាក់ស៊ីម៉ង់ត៍នាំចូលតាមសាឡង់ពីប្រទេសថៃ ដោយដងយោងចល័តនៅផែ។ ក៏ប៉ុន្តែស៊ីម៉ង់ត៍នៅពេលបណ្តោះអាសន្ននេះគឺនាំចូលសម្រាប់តែសាងសង់រោងចក្រអគ្គីសនីនៅតំបន់ដីគោកប៉ុណ្ណោះ។ នៅកំពង់ផែនេះពុំមានទំនិញចេញចូលទៀងទាត់ទេ។ ក្រុមហ៊ុន SEZ មានគម្រោងអភិវឌ្ឍន៍កំពង់ផែថ្មីមួយ ដែលមានចំណតផែជំរៅ ១៨ ម ចំងាយ ១០០ គម ពីភាគអាគ្នេយ៍ខេត្តកោះកុង។




រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-៧: ទីតាំងកំពង់ផែទំនប់រលក**



រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-៨: កំពង់ផែកំពត**



រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-៩: កន្លែងសាងសង់កំពង់ផែកំពតថ្មី**



ប្រភព: Attwood

**រូប ២.៥-១០: គម្រោងអភិវឌ្ឍន៍កំពង់ផែស្ទឹងហាវ**



ប្រភព: Attwood



រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-១១: ការសាងសង់កំពង់ផែថ្មីនៅស្រុកស្ទឹងហាវ**

**រូប ២.៥-១២: កំពង់ផែកោះកុង**

### (២) កំពង់ផែឧកញ៉ាម៉ុង

កំពង់ផែឧកញ៉ាម៉ុងគឺជាកំពង់ផែសមុទ្រឯកជនដំបូងគេនៅកម្ពុជា ថិតនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។ កំពង់ផែនេះបានបើកសម្ពោធនីចាប់ដំណើរការនៅឆ្នាំ ២០០៤។ បច្ចុប្បន្ន កំពង់ផែនេះគ្រប់គ្រងដោយក្រុមហ៊ុនរួមទុនរវាងកម្ពុជា និងថៃ។ កំពង់ផែសាងសង់លើផ្ទៃដីទំហំ ៦៤ ហត (ក្នុងនោះ ២៦ ហត ជាចំណតផែ) ចំណតផែមានប្រវែងសរុប ១.១១១ ម ទទឹក ២០០ ម និងជំរៅទឹក ៥.៥ ម មានឃ្លាំទុកទំនិញ ៦ (ឃ្លាំងមួយទំហំ ១.២០០ម$^2$ ឃ្លាំង ៣ ទៀតទំហំ ៥.៦០០ម ម$^2$ និង ឃ្លាំង ២ ទំហំ ៧.០០០ ម$^2$) ទីលានទុកទំនិញទំហំ ៣ ហត។ កំពង់ផែមានដងយោង ៥ គ្រឿង ( ២៥ តោន ២ គ្រឿង) មានរថយន្តចូក ៥ គ្រឿង និងរថយន្តដឹកទំនិញ ១៥ គ្រឿង (សម្រាប់ដឹកទំនិញនៅទីលានផែ) និងសាឡង់បូមខ្សាច់ ២ គ្រឿង។

ទំនិញចូលផែភាគច្រើនដឹកតាមសាឡង់ ឬ កប៉ាល់ឈើចំណុះ ៣០០ តោន មកពីប្រទេសថៃ។ នៅរយៈពេល ៦ ខែ ពី ខែតុលា ឆ្នាំ ២០១០ មានទំនិញ ៣៧១.០០០ តោន លើកដាក់នៅផែ (ក្នុងនោះ ៣៦៨.២៥៨ តោន ជាទំនិញនាំចូល និង ៣.៦០២ តោន ជាទំនិញនាំចេញ) និងមាននាវា ៥៤១ គ្រឿង ចូលមកកំពង់ផែនេះ។ ទំនិញនាំចូលសំខាន់ឆ្លងកាត់កំពង់ផែនេះជាស៊ីម៉ងត៍ និងស្ករស មកពីប្រទេសថៃ។ នៅកំពង់ផែនេះ ទំនិញនាំចេញមានតែប្រេងដូងឆៅ ដឹកចេញទៅប្រទេសម៉ាឡេស៊ីប៉ុណ្ណោះ។

### (៣) កំពង់ផែស្រែអំបិល

កំពង់ផែស្រែអំបិលថិតនៅស្រុកស្រែអំបិល ខេត្តកោះកុង ចំងាយ ៩៩.៦៩ គម ពីខេត្តព្រះសីហនុ។ ជាកំពង់ផែឯកជនលើផ្ទៃដីទំហំ ១០ ហត ថិតនៅតាមបណ្តោយព្រែកប្រហែល ១២ គម ពីលំហរសមុទ្រ មានប្រវែងចំណតសរុប ៥០០ ម ទទឹង ៣០ ម និងជំរៅទឹក ៥ ម។ ដោយគ្មានការបូមស្អារ កប៉ាល់ចូលតាមព្រែកទៅកំពង់ផែនេះបានចំណុះអតិបរមាត្រឹមតែ ១៨០ តោន តែកំពង់ផែមានគម្រោងរក្សាជំរៅទឹកឱ្យបាន ៦ ម ដោយធ្វើការបូមស្អារ ដើម្បីឱ្យនាវាចំណុះពី ២.០០០ ទៅ ៣.០០០ តោនអាចបើកតាមព្រែកចូលមកកំពង់ផែនេះបាន។ កំពង់ផែមានដងយោង ៥ គ្រឿង និងសាឡង់បូមខ្សាច់ ២ គ្រឿង ឃ្លាំងទំនិញ ៣ ស្ដុបផ្ទេរទំនិញចុះឡើងទំហំ ៤៨ ម$^2$ និងទីលានទុកទំនិញទំហំ ៣ ហត។

ទំនិញភាគច្រើនមកពីប្រទេសថៃ។ ទំនិញនាំចូលឆ្លងកាត់កំពង់ផែស្រែអំបិលនេះមានចំនួនពី ៤.០០០ ទៅ ៥.០០០ តោនក្នុងមួយ។

ចំពោះការលើការដាក់ទំនិញនៅផែ កំពង់ផែមានកម្មករស៊ីឈ្នួលលើកចេញពីនាវាដាក់ចូលទៅរថយន្តផ្ទាល់តែម្តង ដែលកម្មករទាំងនោះ ម្ចាស់ទំនិញ ឬ អ្នកទទួលទំនិញជាអ្នកធ្វើ។

## ២.៥.៣. កំពង់ផែនៅឈូងសមុទ្រសៀម និងវៀតណាមខាងត្បូង

### (១) កំពង់ផែអន្តរជាតិខាយម៉ែប-ធីវ៉ាយ

#### ១) ប្រវត្តិនៃការអភិវឌ្ឍន៍

ឋបនីយភណ្ឌផែសំខាន់របស់ទីក្រុងហូជីមិញ (HCMC) ថិតនៅសងខាងច្រាំងទន្លេសៃហ្គន ចំងាយប្រហែល ៨៥ គម ពីមាត់ទន្លេ ហើយជាប់ទៅនឹងទីប្រជុំជនទីក្រុងដែលមមាញឹក។

ដោយនៅពេលថ្មីៗ សេដ្ឋកិច្ចវៀតណាមមានការរីកលូតលាស់ ធ្វើឱ្យទំនិញចរាចរកាន់តែច្រើនឡើង បង្ករឱ្យមានការកកស្ទះចរាចរកាន់តែធ្ងន់ធ្ងរ និងធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់បរិយាកាសនៅជុំវិញនោះ។ ដើម្បីដឹកជញ្ជូនទំនិញដែលចេះតែកើនឡើងបានច្រើន និងកាត់បន្ថយការបំពុលបរិស្ថាន គេចាំបាច់ត្រូវងាកមកប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹកវិញ។

ក៏ប៉ុន្តែ នៅតាមច្រាំងទន្លេសៃហ្គនពុំមានទីកន្លែងទំនេរគ្រប់គ្រាន់សម្រាប់អភិវឌ្ឍន៍ធ្វើឋបនីយភណ្ឌផែថ្មីបំរើដល់ការដឹកជញ្ជូនតាមផ្លូវទឹកនោះទេ។

ចិតក្នុងស្ថានភាពនេះ រដ្ឋាភិបាលបានសម្រេចអភិវឌ្ឍន៍កំពង់ផែទឹកជ្រៅថ្មីមួយនៅមាត់ទន្លេធីវ៉ាយ នៅឆ្នាំ ១៩៩៩។ តំបន់នេះចិតនៅចំងាយប្រហែល ៧៧ គម ពីទីក្រុងហូជីមិញ បើធ្វើដំណើរតាមផ្លូវថ្នល់។ វាជាតំបន់មានជំរៅទឹកគ្រប់គ្រាន់អាចឱ្យនាវាដឹកកុងតេន័រស៊ីជំរៅទឹកជ្រៅចូលចតបាន។

នៅឆ្នាំ ២០០០ រដ្ឋាភិបាលបានស្នើរសុំ ODA ជប៉ុនឱ្យមកធ្វើការសិក្សាពីសមិទ្ធិលទ្ធកម្មដើម្បីអភិវឌ្ឍន៍កំពង់ផែទឹកជ្រៅថ្មីមួយ។ ក្រោយពីសិក្សារួច រដ្ឋាភិបាលបានស្នើរសុំហិរញ្ញប្បទាន ODA ជប៉ុនម្តងទៀតសម្រាប់គម្រោងអភិវឌ្ឍន៍នោះ។

ឆ្លើយតបទៅនឹងដំណើរការគម្រោងអភិវឌ្ឍន៍នេះក្រុមហ៊ុនប្រតិបត្តិករបរទេសនិងក្រុមហ៊ុនកប៉ាល់បានចាប់ផ្តើមវិនិយោគធ្វើចំណតផែកុងតេន័រ និងធ្វើអាជីវកម្មគ្រប់គ្រង និងធ្វើប្រតិបត្តិការផែ ដោយបណ្តាក់ទុនរួមគ្នាជាមួយសាជីវកម្មវៀតណាម។

**២) ទីតាំង និងគម្រោងបួងទូទៅរបស់ CTs និងផ្លូវចូល**

បរិវេណនៅតាមច្រាំងទន្លេគឺគេទុកសម្រាប់អភិវឌ្ឍន៍ធ្វើជាចំណតផែទំនិញចាក់ធារ និងចំណតផែកុងតេន័រនៅខាយម៉ែប-ធីវ៉ាយ ដូចមានបង្ហាញក្នុងរូប ២.៥-១៣។ ក្នុងរូបនេះចំណតផែសំគាល់ដោយបន្ទាត់គូសពីក្រោមជាចំណតផែកុងតេន័រ។ ក្នុងចំនោមចំណតផែទាំងនោះ ចំណតផែក្រោមកម្ចីហិរញ្ញប្បទាន ODA ជប៉ុន និងចំណតផែសៃហ្គន SSA នឹងចាប់បើកដំណើរការនៅឆ្នាំ ២០១២។ ចំណតផែ Germalink ត្រូវបានលើកពេលសាងសង់ ចំណែកគម្រោងសាងសង់ចំណតផែខាយម៉ែបខ្សែទឹកខាងក្រោមត្រូវបានលុបចោល។

នៅពីក្រោយ ឬ នៅជាប់នឹងច្រាំងទន្លេ គេសាងសង់សួនឧស្សាហកម្ម ដើម្បីងាយស្រួលដឹកជញ្ជូនទំនិញតាមឋបនីយភណ្ឌផែដែលមាននៅទីនោះស្រាប់។ ទន្លេមានទទឹងពី ៤០០ ម ទៅ ៦០០ ម ក្នុងបរិវេណ CTs។ នៅខ្សែទឹកខាងក្រោមនៃ TCCT/TCIT មានជំរៅទឹក ១៤ ម និង ១២ ម នៅខ្សែទឹកខាងលើ។




ប្រភព: VICT (ផែកុងតេន័រអន្តរជាតិវៀតណាម)

**រូប ២.៥-១៣: ទីតាំងចំណតផែនៅតំបន់ខាយម៉ែប-ធីវ៉ាយ**

ផ្លូវចូលពីទីក្រុងហូជីមិញអាចធ្វើដំណើរតាមផ្លូវជាតិលេខ ១ និង លេខ ៥១ ដូចមានបង្ហាញដោយបន្ទាត់ជិតខ្មៅ (មើល រូប ២.៥-១៤) ចំងាយសរុបប្រហែល ៧៧ គម ។ ផ្លូវជាតិលេខ ៥១ ផ្នែកខ្លះកំពុងកែលំអរដោយពង្រីកផ្លូវពី ៤ ជួរទៅ ៦ ជួរ ។ តែកៅស៊ូវក្រាលថ្នល់មិនមានការថែទាំជិតដល់ទេ ជាលទ្ធផលធ្វើឱ្យរថយន្តដឹកកុងតេន័រចំណាយពេលជិត ៣ ម៉ោង ធ្វើដំណើរពីទីក្រុងហូជីមិញទៅកំពង់ផែខាយម៉ែប-ធីវ៉ាយ ។ ដើម្បីឱ្យការប្រើប្រាស់កំពង់ផែខាយម៉ែប-ធីវ៉ាយមានប្រសិទ្ធិភាព គេចាំបាច់ធ្វើផ្លូវថ្នល់ឱ្យមានលក្ខណៈល្អប្រសើរ និងងាយស្រួលមួយកម្រិតទៀត ។

សាឡង់ត្រូវធ្វើដំណើរចំងាយ ៦៥ គម ឆ្លងកាត់ទន្លេពីទីក្រុងហូជីមិញ មកកំពង់ផែដូចមានបង្ហាញក្នុងរូប ២.៥-១៤។ បច្ចុប្បន្ន កុងតេន័រ ៨០% ដែលត្រូវលើកដាក់ចូលនាវាកុងតេន័រនៅកំពង់ផែត្រូវដឹកតាមសាឡង់ផ្ទុកបាន ៥០ TEU ។ នេះដោយសារការដឹកជញ្ជូនតាមផ្លូវថ្នល់មានការលំបាក មានការរឹតបណ្តឹងចំពោះការដឹកជញ្ជូនតាមរថយន្តនៅទីប្រជុំជនទីក្រុងហូជីមិញ ដែលអាចបើកបានពីម៉ោង ៦:០០-៩:០០ ព្រឹក និងពី ១៦:០០-២១:០០ រសៀល ។




ប្រភព: VICT

**រូប ២.៥-១៤: ផ្លូវចូលទៅកំពង់ផែខាយម៉ែប-ធីវ៉ាយ**

### ៣) ប្រតិបត្តិការចំណតផែ និងការជាប់ពាក់ពន្ធ័របស់សាជីវកម្មកំពង់ផែសៃហ្គនថ្មី

តារាង ២.៥-៥ បង្ហាញពីឈ្មោះក្រុមហ៊ុន លក្ខណៈពិសេស និងសមត្ថភាពចំណតផែកុងតេន័រនៅកំពង់ផែខាយម៉ែប-ធីវ៉ាយ ។ សហគ្រាសសាធារណៈដូចជា កំពង់ផែសៃហ្គនថ្មី កំពង់ផែសៃហ្គន ក្រុមហ៊ុន Vinalines ជាអ្នកធ្វើប្រតិបត្តិការផ្ទាល់មុខលើចំណតផែកុងតេន័រទាំងនោះ ឬ ជាសមាជិកនៃការបណ្តាក់ទុនរួមគ្នាជាមួយក្រុមហ៊ុនប្រតិបត្តិករចំណតផែឯកជន។ សមត្ថភាពលើកដាក់កុងតេន័រសរុបនៅកំពង់ផែខាយម៉ែប-ធីវ៉ាយ ក្រោយពីបញ្ចប់ការសាងសង់ចំណតផែ ២ ដែលបច្ចុប្បន្នកំពុងសាងសង់ គេរំពឹងថានឹងកើនទៅដល់យ៉ាងហោចណាស់ ៦.៧៥ លាន TEUs ។

**តារាង ២.៥-៥: ចំណតផែកុងតេន័រនៅកំពង់ផែខាយម៉ែប-ធីវ៉ាយ**

Particular of Container Terminals at Cai Mep-Thi Vai Area

| No | Name of Terminal | Name of Holders | Operation Year | Length | Berth Depth | Channel Depth | Area | Max. Ship Size | Capacity (TEU/year) |
|---|---|---|---|---|---|---|---|---|---|
| 1 | Saigon International Terminal Vietnam (SITV) | Saigon New Port Co.,(30%) /Hutchison Port Holdings (HPH) (70%) | August 2010 | 730 m | 14 m | 12 m | 33 ha | 80,000 DWT | na |
| 2 | Saigon Port-PSA International Port (SP-PSA) | Saigon Port / Vinalines/ PSA | 2009 | 600 m (600 m; extension) | 14.5 m | 12 m | na | 80,000 DWT | 2 m. TEU/ 1,200 m Record; 96,000 TEU (2009) 293,912TEU (2010) |
| 3 | Tang Cang Cai Mep Container Terminal (TCCT)/ Tan Cang Cai Mep International Container Terminal (TCIT) | Saigon New Port (100%) (TCCT)/ | June 2009 | 300 m | 14 m | 12 m | na | na | 0.6 m. TEU |
| | | Hanjin(20%)/MOL(20 %)/Wan Hai(20%)/ Saigon New Port(35%) (TCIT) | March 2011 | 590 m | 14 m | 12 m | 40 ha | 10,000TEU | 1.15 m. TEU |
| 4 | Cai Mep International Terminal (CMIT) | Vinalines+Saigon Port(51%) / APMT(49%) | March 2011 | 600 m | 16.5 m | 14 m (16.5 m; future) | 36 ha | 15,000 TEU | 1.1 m. TEU |
| 5 | Cai Mep International Container- Japan ODA | Ministry of Transport | Under construction | 600 m | 15 m | 14 m | 76 ha | 80,000 -100,000 DWT | 0.7 m. TEU |
| 6 | Saigon Port-SSA International Terminal (SSIT) | Saigon Port/ SSA/ Vinalines | Under construction | 600 m | 14 m | 14 m | na | 10,000TEU + | 1.2 m. TEU |

(Source-Project Team)

រៀបចំដោយក្រុមសិក្សាគម្រោង

### (២) កំពង់ផែនៅទីក្រុងហូជីមិញ

#### ១) លក្ខណៈទូទៅ

ចំណតផែនៅទីក្រុងហូជីមិញឋិតនៅតាមដងទន្លេក្នុងទីក្រុងហូជីមិញ ចំងាយប្រហែល ៤៥ ម៉ាល៍នាវាចរណ៍ពីសមុទ្រ។ នៅសម័យអាណានិគមបារាំងក្នុងឆ្នាំ ១៨៦០ កំពង់ផែពាណិជ្ជកម្មសៃហ្គនបានស្ថាបនាឡើង ហើយចាប់ពីពេលនោះមក កំពង់ផែនេះបានបំរើជាកន្លែងធ្វើពាណិជ្ជកម្មជាមួយតំបន់ដីគោកដ៏ធំមួយ មានដូចជាសៃហ្គន (ហូជីមិញ) ខេត្តផ្សេងៗនៅជាប់កំពង់ផែនេះ និងតំបន់ដីសណ្តរទន្លេមេគង្គ។ មុនទទួលបានឯករាជពីបារាំង កំពង់ផែនេះជាច្រកផ្លូវសំខាន់សម្រាប់រណ្តចិនបារាំងរួមទាំងកម្ពុជាផងដែរ។

ទីតាំងចំណតផែកុងតេន័រសំខាន់ៗនៅទីក្រុងហូជីមិញមានបង្ហាញក្នុងរូប ២.៥-១៥។ ចំណតផែខាត់ឡៃកាន់កាប់ដោយកំពង់ផែសៃហ្គនថ្មីដើមឡើយជារបស់កងទ័ពជើងទឹក គឺជាចំណតផែធំជាងគេនៅទីក្រុងហូជីមិញ ក៏ដូចជានៅវៀតណាមដែរ។ VICT ជាចំណតផែកុងតេន័រឯកជនដំបូងគេនៅកំពង់ផែនេះ។ កំពង់ផែសៃហ្គនកាន់កាប់ដោយក្រុមហ៊ុនកំពង់ផែសៃហ្គន។ កំពង់ផែប៊ិនញ៉េ (Ben Nghe) ឋិតនៅជាប់កំពង់ផែ VICT ធ្វើប្រតិបត្តិការសំខាន់ខាងលើកដាក់កុងតេន័រក្នុងស្រុក។ ចំណតផែហៀបផូក (Hiep Phuoc) ជាចំណតផែថ្មីជាងគេ និងមានចំណតទឹកជ្រៅជាងគេនៅកំពង់ផែហូជីមិញ។ ចំណតផែទាំងអស់នៅកំពង់ផែហូជីមិញ ក្រៅពីកំពង់ផែហៀបផូក ប្រើប្រឡាយទឹកឡុងតៅ (Long Tau) ជំរៅទឹក ៨.៥ ម ចំណែកចំណតផែហៀបផូក គ្រោងប្រើព្រែក Soai Rap ដោយជីកឱ្យមានជំរៅដល់ -៩.៥ ម (នូវ៉ូទឹកជោរ ឬ នាច -១២ម)។

ដូចបានលើកឡើងពីខាងលើ ICDs ឋិតនៅដងទន្លេដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនកុងតេន័រនៅវៀតណាមខាងត្បូង។ ដោយសារស្ថានភាពផ្លូវមិនល្អនៅតំបន់ខាយម៉េប-ធីវ៉ាយ ចាំបាច់ត្រូវផ្ទេរទៅដឹកតាមទ្បានកុងតេន័រនៅទីប្រជុំជនទីក្រុង មានកុងតេន័រច្រើនសន្ធឹកគេលើកដាក់នៅ ICDs ហើយដឹកពី ICDs ទៅខាយម៉េប ឬ ចំណតផែផ្សេងទៀតនៅកំពង់ផែហូជីមិញតាមសាឡង់។

តារាង ២.៥-៦ បង្ហាញពីចំនួនកុងតេន័រឆ្លងកាត់ផែសរុបនៅកំពង់ផែហូជីមិញ។ កំពង់ផែហូជីមិញលើកដាក់កុងតេន័របានច្រើនជាងកំពង់ផែខាយម៉េប-ធីវ៉ាយ។ គួរកត់សំគាល់ដែរថាស្ថិតិមានទាំងចំនួនកុងតេន័រដឹកតាមសាឡង់ផងដែរ។ ដូចនេះលំហូកុងតេន័រសុទ្ធឆ្លងកាត់កំពង់ផែហូជីមិញមានចំនួនតិចជាង ដូចមានបង្ហាញក្នុងតារាង។




រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-១៥: ចំណតផែនៅកំពង់ផែហូជីមិញ**

**តារាង ២.៥-៦: ចំនួនកុងតេន័រឆ្លងកាត់ផែនៅហូជីមិញ**

| Year | Throughput (TEU) |
|---|---|
| 2006 | 2,327,831 |
| 2007 | 3,172,000 |
| 2008 | 3,432,000 |
| 2009 | 3,563,246 |
| 2010 | 3,856,000 |

ប្រភព: ci online

### ២) កំពង់ផែខាត់ឡៃ

កំពង់ផែខាត់ឡៃប្រតិបត្តិការដោយកំពង់ផែសៃហ្គនថ្មីគឺជាកំពង់ផែកុងតេន័រធំជាងគេនៅវៀតណាម បើគិតទៅតាមបរិមាណកុងតេន័រដែលកំពង់ផែនេះលើកដាក់បាន។ កំពង់ផែនេះតភ្ជាប់ពីសមុទ្រក្រៅតាមរយៈព្រែកជីកជាប្រឡាយទឹកសម្រាប់នាវាបើកចេញចូលចំងាយផ្លូវទឹក ៤៣ ម៉ាល ជំរៅទឹក ៨.៥ ម។ ត្រឹមតែកំពស់ទឹកជោរ-នាចជាមធ្យម ៤ ម ប្រឡាយនាវាចរណ៍អាចឱ្យនាវាចំណុះ ៣០.៧៩០ DWT ស៊ីជំរៅទឹកអតិបរមា ១១ ម បើកបរបាន។

កំពង់ផែមានផ្ទៃដីសរុប ៨០ ហត។ ដូចបានបង្ហាញក្នុងរូប ២.៥-១៦ កំពង់ផែមានចំណតផែ ២: ចំណតផែ A ប្រវែង ៣០៣ និងចំណតផែ B ប្រវែង ៦៧០ ម។ ជំរៅទឹកនៅតាមច្រាំងចំណតផែទាំងពីរគឺ ១១.៥ ម។ នៅចន្លោះចំណតផែទាំងពីរគឺចំណតផែប្រេង និងអាងស្តុកប្រេងបច្ចុប្បន្ន។ បំបនីយភណ្ឌសម្រាប់បូមប្រេងនឹងត្រូវរើចេញនៅឆ្នាំ ២០១២ ដើម្បីយកកន្លែងអភិវឌ្ឍន៍ធ្វើជាទីលានកុងតេន័រ និងច្រាំងចំណតកុងតេន័រ។

សមត្ថភាពលើកដាក់បច្ចុប្បន្នរបស់កំពង់ផែនេះគឺ ២.៥ លាន TEUs។




ប្រភព: SNP

**រូប ២.៥-១៦: គម្រោងប្លង់បំបនីយភណ្ឌនៅកំពង់ផែខាត់ឡៃ**

### ៣) ចំណតផែកុងតេន័រអន្តរជាតិវៀតណាម

ចំណតផែកុងតេន័រអន្តរជាតិវៀតណាម (VICT) ឋិតនៅជាប់តំបន់ជំរុញការនាំចេញថាន់ធួន (Tan Thuan Export Processing Zone) ចំងាយ ៦ គម នៅខ្សែទឹកខាងក្រោមទន្លេសៃហ្គនពីទីក្រុងហូជីមិញ។

ខុសគ្នាពីចំណតផែកុងតេន័រផ្សេងទៀតនៅកំពង់ផែហូជីមិញ VICT គឺក្រុមហ៊ុនឯកជនជាអ្នកកាន់កាប់ និងធ្វើប្រតិបត្តិការផ្ទាល់ក្រោមច្បាប់វិនិយោគពីបរទេសរបស់វៀតណាម។ ជាគម្រោងសាងសង់កំពង់ផែសម្រាប់តែកុងតេន័រដំបូងគេនៅវៀតណាមដែលមានដៃគូរបរទេសចូលរួម។

ចំណតផែនេះមានផ្ទៃដីទំហំ ២០ ហត និងច្រាំងចំណតប្រវែង ៦៧៨ ម។ ទឹកនៅតាមច្រាំងចំណតមានជំរៅ ១១.២ ម អាចឱ្យនាវាកុងតេន័រចំណុះ ២៥.000 DWT ចូលចតបាន។ ចំណតផែនេះមានដងយោងធន់ធ្ងន់នៅច្រាំងចំណត ៧ គ្រឿង និង RTGs ១៧ គ្រឿង។ ការសាងសង់បានបញ្ចប់នៅឆ្នាំ ២០០៩។

រូប ២.៥-១៨ និង រូប ២.៥-១៩ បង្ហាញពីចំនួនកុងតេន័រឆ្លងកាត់ផែ និងចំនួននាវាចេញចូលផែ។ មកដល់ឆ្នាំ ២០០៧ ចំនួនកុងតេន័រឆ្លងកាត់បានកើនឡើងជាលំដាប់ តែបានថយចុះបន្តិចក្រោយពីឆ្នាំ ២០០៨ ព្រោះកំពង់ផែបានបាត់បង់ចរាចរកុងតេន័រច្រើនសន្ធឹកនៅឆ្នាំ ២០០៩ ដោយសារមានការដាក់កំហិតផ្លូវចេញចូលផែនៅពេលសាងសង់ស្ពានកាត់ប្រឡាយនាវាចរណ៍។ ស្ពាននោះសាងសង់ហើយនៅឆ្នាំ ២០១០ តែចរាចរកុងតេន័រមិនទាន់កើនឡើងមកវិញនៅកំពង់ផែនេះនៅឡើយ។



ប្រភព: VICT

**រូប ២.៥-១៧: គម្រោងប្លង់ឋបនីយភណ្ឌនៅចំណតផែកុងតេន័រអន្តរជាតិវៀតណាម**




ប្រភព: VICT

**រូប ២.៥-១៨: ចំនួនកុងតេន័រឆ្លងកាត់ផែ VICT**




ប្រភព: VICT

**រូប ២.៥-១៩: ចំនួននាវាប្រចាំឆ្នាំនៅ VICT**

### (៣) កំពង់ផែឡាំឆាបាង

### ១) ទិដ្ឋភាពទូទៅ

កំពង់ផែឡាំឆាបាងគឺនៅខេត្តឈុនបូរីប្រទេសថៃ ចំងាយប្រហែល ១៣០ គម ភាគអគ្នេយ៍ទីក្រុងបាងកក។ កំពង់ផែនេះ ចិតនៅតាមខ្សែឆ្នេរសមុទ្រខាងកើត ដែលជាតំបន់មានសេដ្ឋកិច្ចលេចធ្លោជាងគេក្នុងប្រទេស។ ជាកំពង់ផែធំជាងគេនៅក្នុងប្រទេស ចាប់តាំងពីបានបើកដំណើរការមកនៅឆ្នាំ ១៩៩១ បច្ចុប្បន្ន កំពង់ផែនេះមានកុងតេន័រឆ្លងកាត់ជាប់លំដាប់ថ្នាក់ទី ២២ នៅលើពិភពលោក។

ICD ឡាតក្រាបាង ចិតនៅចន្លោះកំពង់ផែឡាំឆាបាង និងទីប្រជុំជនទីក្រុងបាកក បំពេញមុខងារជាកំពង់ផែស្ងួតសម្រាប់កំពង់ផែឡាំឆាបាងនេះ។ ការពិពណ៌នាលំអិតពី ICD នេះមាននៅក្នុងចំណុច ៦) ខាងក្រោម។




ប្រភព: Google ក្រុមសិក្សាគម្រោង

**រូប ២.៥-២០: ទីតាំងកំពង់ផែឡាំឆាបាង**

### ២) ប្រវត្តិនៃការអភិវឌ្ឍន៍

នៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ រដ្ឋាភិបាលថៃយល់ឃើញថា ដោយកំពង់ផែបាងកកមិនអាចបំពេញតម្រូវការសេដ្ឋកិច្ច

រយៈពេលវែងរបស់ប្រទេសបាន គេចាំបាច់ត្រូវបង្កើតឱ្យមានកំពង់ផែសមុទ្រទឹកជ្រៅថ្មីមួយទៀតនៅឡាំឆាបាង។

ផែនការមេនៃ"កម្មវិធីអភិវឌ្ឍន៍តំបន់ឆ្នេរភាគខាងកើត" រួមទាំងការអភិវឌ្ឍន៍កំពង់ផែឡាំឆាបាងទទួលបានការអនុម័ត្រ ពីគណៈរដ្ឋមន្ត្រីនៅឆ្នាំ ១៩៨២។ ក្រោមផែនការមេនេះ "គណៈកម្មាធិការអភិវឌ្ឍន៍តំបន់ឆ្នេរភាគខាងកើត (ESDC)"បាន បង្កើតឡើងលក្ខណៈជាគណៈកម្មាធិការជាតិកម្រិតគណៈរដ្ឋមន្ត្រី ដោយយល់ឃើញថាកំពង់ផែត្រូវអភិវឌ្ឍន៍រួមគ្នាជាមួយ តំបន់ឧស្សាហកម្មដីគោក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតភ្ជាប់តំបន់ឆ្នេរសមុទ្រខាងកើតទៅតំបន់ទីប្រជុំជនទីក្រុងបាងកក។

សហគ្រាសឯកជនផ្សេងៗត្រូវគេស្វាគមន៍ឱ្យចូលរួមធ្វើប្រតិបត្តិការចំណតផែក្រោមអភិបាលកិច្ចរួមរបស់អាជ្ញាធរផែថៃ។

**៣) ឋបនីយភណ្ឌ**

គម្រោងប្លង់ចំណតផែដែលកំពុងដំណើរការបច្ចុប្បន្ន និងគម្រោងពង្រីកទៅអនាគតមានបង្ហាញក្នុងរូប ២.៥-២១ (ក្នុង រូបនេះក៏មានបង្ហាញពីសម្បទានិកនីមួយៗដែលជាម្ចាស់ហ៊ុនបរទេសផងដែរ)។

នៅជុំវិញជលសីមា I (Basin I) មានចំណតផែចំនួន ១១ និងនៅជលសីមា II (Basin II) មានចំនួនចំណតផែបួន (C0, C1, C2, C3) បច្ចុប្បន្នកំពុងដំណើរការ។ ជលសីមា I ដែលបានសាងសង់ក្នុងផែនការអភិវឌ្ឍន៍ដំណាក់កាលទី ១ បានចាប់ ផ្តើមដំណើរការនៅឆ្នាំ ១៩៩១ ឱ្យនាវាចេញចូលបាន ៤ លាន TEUsក្នុងមួយឆ្នាំ។ ករណីជលសីមា II គ្រោងនឹងធ្វើនៅដំណាក់ កាលទី ២ ការងារវិស្វកម្មបានធ្វើរួចរាល់ហើយដោយក្រុមហ៊ុន Hutchison Port Holdings ដែលជាសម្បទានិកតែមួយ និងបានផ្តល់ឱ្យក្រុមហ៊ុនដដែលករណីកំពង់ផែដែលបានធ្វើដំបូងគេ ខណៈពេលចំណតផែ ៣ ទៀត (D1, D2, D3) នៅកំពុង សាងសង់នៅឡើយ បើទោះណាតាមកិច្ចសន្យាសម្បទានពីដើមមកកំណត់ឱ្យចំណតផែទាំងអស់ត្រូវសាងសង់ឱ្យរួចរាល់អាច ចាប់ដំណើរការនៅឆ្នាំ ២០១១ ក៏ដោយ។ បើគេប្រើជលសីមា II ឱ្យអស់លទ្ធភាព នោះកំពង់ផែនឹងអាចបង្កើនសមត្ថភាពលើក ដាក់សរុបរបស់ខ្លួនបានរហូតទៅដល់ ១០.៨ លាន TEUs ក្នុងមួយឆ្នាំ។

វិនិយោគិនបរទេសមានសិទ្ធិបង្កើតក្រុមហ៊ុនសម្បទានិកដែលមានហ៊ុនភាគច្រើនជារបស់ក្រុមហ៊ុនក្នុងស្រុកចុះបញ្ជីក្នុង ប្រទេសថៃ។ រូប ២.៥-២២ បង្ហាញពីគម្រោងប្លង់ជលសីមា និងចំណតផែជាមួយឈ្មោះម្ចាស់ហ៊ុនបរទេស។ ពត៌មានលំអិត ពីសម្បទានិក និងឋបនីយភណ្ឌផ្សេងៗមានបង្ហាញក្នុងតារាង ២.៥-៧។




រៀបចំដោយក្រុមសិក្សាគម្រោង

**រូប ២.៥-២១: គម្រោងប្លង់ចំណតផែ និងសម្បទានិកម្ចាស់ហ៊ុនបរទេស**

**តារាង ២.៥-៧: ឋបនីយកណ្ឌ និងសម្បទានិកចំណតផែ**

| Basin | Terminal | Type of Terminal | Facilities | | | Concessionaires | | |
|---|---|---|---|---|---|---|---|---|
| | | | Length (m) | Depth (m) | Number of gantry cranes | Name of Company | Contract effected | Valid years |
| | A0 | Multi Purpose | 590 | 10 | — | LCMT Co., Ltd. | 2004 | 30 |
| | A1 | Cruise ships & RoRo | 365 | 14 | — | Laem Chabang Cruises Center Co., Ltd. | 2000 | 30 |
| | A2 | Containers | 400 | 14 | 8 | Thai Laem Chabang Terminal Co., Ltd. | 1996 | 30 |
| | A3 | Containers | 350 | 14 | | Hutchison Laem Chabang Terminal Co., Ltd. | 2004 | 30 |
| | A4 | Conventional | 250 | 14 | — | Aawthai Warehouse Co., Ltd. | 1996 | 25 |
| I | A5 | RoRo | 450 | 14 | — | Namyong Terminal Co., Ltd. | 1996 | 25 |
| | B1 | Containers | 300 | 14 | 6 | LCB Container Terminal 1 Co., Ltd. | 1995 | 27 |
| | B2 | Containers | 300 | 14 | 3 | Evergreen Container Terminal (Thailand) Co., ltd. | 1993 | 27 |
| | B3 | Containers | 300 | 14 | 4 | Eastern Sea Laem Chabang Terminal Co., ltd. | 1995 | 27 |
| | B4 | Containers | 300 | 14 | 5 | TIPS Co., ltd. | 1995 | 27 |
| | B5 | Containers | 400 | 14 | 4 | Laem Chabang International Terminal Co., ltd. | 1996 | 30 |
| | C0 | Containers | 400 | 16 | — | — | | |
| | C1 | Containers | 700 | 16 | 12 | Hutchison Laem Chabang Terminal Co., Ltd. | 2004 | 30 |
| | C2 | Containers | 500 | 16 | | Hutchison Laem Chabang Terminal Co., Ltd. | 2004 | 30 |
| II | C3 | Containers | 500 | 16 | 4 | Laem Chabang International Terminal Co., ltd. | 2003 | 30 |
| | D1 | Containers | 500 | 16 | — | Hutchison Laem Chabang Terminal Co., Ltd. | 2004 | 30 |
| | D2 | Containers | 500 | 16 | — | Hutchison Laem Chabang Terminal Co., Ltd. | 2004 | 30 |
| | D3 | Containers | 500 | 16 | — | Hutchison Laem Chabang Terminal Co., Ltd. | 2004 | 30 |

ប្រភព: PAT

## ៤) ទំនិញឆ្លងកាត់ផែ

តារាង ២.៥-៨ បង្ហាញពីប្រវត្តិកំនើនទំនិញឆ្លងកាត់ផែ ។

**តារាង ២.៥-៨: ចំនួនទំនិញកំពង់ផែឡាំឆាបាងលើកដាក់បាន**

| Discription | Unit | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|
| Number of vessel calls | calls | 5,112 | 6,149 | 6,645 | 7,012 | 6,288 | n/a |
| Total volume of cargoes | | | | | | | |
| Import | million tons | 12,604 | 13,415 | 15,478 | 20,150 | 15,791 | n/a |
| Export | million tons | 22,891 | 24,907 | 29,114 | 34,411 | 31,190 | |
| Transhipment | million tons | 239 | 134 | 272 | 276 | 107 | |
| Total | million tons | 35,734 | 38,456 | 44,864 | 54,837 | 47,088 | |
| Container throughput | | | | | | | |
| Import laden | '000 TEUs | 806 | 842 | 975 | 1,266 | 990 | 1,312 |
| Export laden | '000 TEUs | 1,877 | 2,037 | 2,311 | 2,614 | 2,272 | 2,673 |
| Empties (Import+Export) | '000 TEUs | 1,082 | 1,244 | 1,355 | 1,360 | 1,360 | 1,205 |
| Total | '000 TEUs | 3,765 | 4,123 | 4,641 | 5,240 | 4,622 | 5,190 |
| Number of vehicles handled | | | | | | | |
| Import | '000 units | 38 | 42 | 54 | 62 | 43 | n/a |
| Export | '000 units | 410 | 525 | 643 | 799 | 534 | |
| Total | '000 units | 448 | 567 | 697 | 862 | 577 | |

កំណត់សំគាល់: ឆ្នាំក្នុងតារាងជាឆ្នាំសារពើពន្ធរបស់ PAT គិតពីថ្ងៃទី ១ ខែតុលា ដល់ថ្ងៃទី ៣០ ខែ កញ្ញា លើកលែងឆ្នាំ ២០១០ ។
ប្រភព: PAT សមាគមទីភ្នាក់ងារ និងម្ចាស់នាវាបាងកក

កំពង់ផែលើកដាក់រថយន្តនាំចេញចំនួនច្រើនសន្ធឹកគួរឱ្យកត់សំគាល់ ។ ដោយទទួលបានអត្ថប្រយោជន៍ពីការធ្វើសមាហរណ៍កម្មក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងផ្សំសម្រាប់ដំឡើងជាផលិតផលសម្រេចដែលមានការអភិវឌ្ឍន៍ខ្លាំងក្លានៅក្បែរៗគ្នានោះ ក្រុមហ៊ុនផលិតរថយន្តនៅប្រទេសថៃបានពង្រីកទីផ្សារនាំចេញរថយន្តទៅប្រទេសដៃគូរនាំចេញរបស់ខ្លួនបានយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក ។

រថយន្តសរុបចំនួន ៥៧៧ គ្រឿង ត្រូវបាននាំចេញពីកំពង់ផែនេះនៅឆ្នាំ ២០០៩ តែចំនួននេះនៅតិចជាងការនាំចេញច្រើនបំផុតនៅឆ្នាំ ២០០៨។ គេតំឡើងរថយន្តក្នុងរោងចក្រតំឡើងរថយន្តនៅតំបន់ពាណិជ្ជកម្មតាមឆ្នេរសមុទ្រភាគខាងកើត និងតំបន់ជាយក្រុងបាងកកនៅឆ្ងាយជាងគេចំងាយ ២៥០ គម ពីកំពង់ផែ។ ថបនីយភណ្ឌផែសម្រាប់លើកដាក់រថយន្តមានចំណតផែ Ro-Ro (បើកចូល-បើកចេញ) និងចំណតរថយន្តដែលមានកន្លែងត្រួតពិនិត្យមុនពេលនាំចេញយកទៅចែកចាយ (PDI) ដូចមានបង្ហាញក្នុងរូប ២.៥-២២ ខាងក្រោម ។




ប្រភព: PAT

**រូប ២.៥-២២: គម្រោងប្លង់ចំណតផែ និងទីលានទុករថយន្ត**

### ៥) ផែនការអភិវឌ្ឍន៍

ផែនការអភិវឌ្ឍន៍ដំណាក់កាលទី ៣ បច្ចុប្បន្នកំពុងដំណើរការសាងសង់ជលសីមាបន្ថែមមួយទៀត (គឺជលសីមា III) ដែលមានចំណតផែ ៦ កន្លែង។ PAT ជាអ្នកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ចំណែកឧបរិរចនាសម្ព័ន្ធ សម្បទានិកជាអ្នកអភិវឌ្ឍន៍។ ផែនការនេះនឹងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រីនៅត្រីមាសទី ៣ ឆ្នាំ ២០១២ បន្ទាប់មកនឹងដាក់ឱ្យដេញថ្លៃសម្រាប់សម្បទានិកនៅពាក់កណ្ដាលឆ្នាំ ២០១៣។ ការងារសាងសង់ជលសីមា III ត្រូវការរយៈពេល ៣ ឆ្នាំកន្លះ ទើបបញ្ចប់ដាក់ឱ្យដំណើរការនៅឆ្នាំ ២០១៧។ បន្ទាប់ពីបើកដំណើរការជលសីមា III សមត្ថភាពលើកដាក់ទំនិញសរុបនៅជលសីមាទាំងបីនឹងកើនទៅដល់ ២០ លាន TEUs ក្នុងមួយឆ្នាំ ច្រើនជាងបួនដងនៃចំនួនទំនិញលើកដាក់បានបច្ចុប្បន្ន។ តាមការព្យាករណ៍របស់ PAT ទំនិញឆ្លងកាត់ផែនឹងកើនទៅដល់ ១០ លាន TEUs នៅឆ្នាំ ២០១៩ និងបន្ទាប់មកនឹងកើនឡើងពី ៨ ទៅ ១០% ក្នុងមួយឆ្នាំ។

### ៦) ICD ឡាត់ក្រាបាង

ដេប៉ូកុងតេន័រជីគោក (ICD) នៅឡាត់ក្រាបាងចិតនៅចំងាយប្រហែល ៣០ គម ភាគខាងកើតកំពង់ផែបាងកក ចំងាយ ១១០ គម ពីកំពង់ផែឡាំឆាបាង។ ICD ប្រើប្រាស់ដោយអាជ្ញាធរអាយស្ម័យយានរដ្ឋថៃ (SRT) ក្នុងផែនការមេនៃកម្មវិធីអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រភាគខាងកើត។

ICDជាកន្លែងទុកទំនិញសម្រាប់ក្រុមហ៊ុនខ្សែដឹកជញ្ជូនទៅយក/ចែកចាយទំនិញ FCL/LCL បន្តពីកំពង់ផែឡាំឆាបាង។ ក្រុមហ៊ុនរកទំនិញដឹក/ម្ចាស់ទំនិញធំៗដែលប្រើ ICD នេះគឺជាបណ្ដាក្រុមហ៊ុនផលិតកម្មនៅតំបន់ឧស្សាហកម្មជាយក្រុងភាគខាងត្បូងទីក្រុងបាងកក នៅដាច់ស្រយ៉ាលបន្តិចពីឡាំឆាបាង។

ICD មានកន្លែងរថភ្លើងចូលចតចេញពីផ្លូវរថភ្លើងរបស់ SRT សម្រាប់ខ្សែរថភ្លើងពីទីក្រុងបាងកក-ឆាឈឿនសៅ និងមានផ្លូវថ្នល់តភ្ជាប់ជាមួយផ្លូវយន្តបទសំខាន់ពីកំពង់ផែឡាំឆាបាងទៅទីប្រជុំជនទីក្រុងបាងកក និងតំបន់ឧស្សាហកម្មភាគខាង

ជើង ។ នៅក្បែរនេះក៏មានអាកាសយានដ្ឋានសុវណ្ណភូមិបាងកកផងដែរ ។




ប្រភព: Eastern Sea Laem Chabang Terminal Co., Ltd.

**រូប ២.៥-២៣: ទីតាំង ICD ឡាត់ក្រាបាង**

ICD ទំហំ ២.៦ គម² ចែកចេញជា ៦ មណ្ឌល ជួលទៅឱ្យក្រុមហ៊ុនខុសៗគ្នា ៦ ធ្វើប្រតិបត្តិការ ។ ផ្លូវរថភ្លើងនៅចំកណ្តាល ដូចនេះក្រុមហ៊ុននៅតាមមណ្ឌលនីមួយៗងាយស្រួលចល័តកុងតេន័រឡើងចុះទូរទេះភ្លើង ។




ប្រភព: Google ក្រុមសិក្សាគម្រោង

**រូប ២.៥-២៤: គម្រោងប្លង់មណ្ឌលក្នុងដេប៉ូងកុងតេន័រជីគោក និងផ្លូវចរាចរចេញចូល**

តារាង ២.៥-៩ បង្ហាញពីទំនិញឆ្លងកាត់ ICD តាមប្រភេទមធ្យោបាយដឹកជញ្ជូនផ្សេងៗ។ ICD លើកដាក់ទំនិញបាន ១.៥ លោន TEUs នៅឆ្នាំ ២០១០ ប្រហែល ៣០% នៃទំនិញឆ្លងកាត់សរុបនៅកំពង់ផែឡាំឆាបាង។ ក្នុង ១.៥ លាន TEUs នោះ មាន 0.៤ លាន TEUs (ស្មើរនឹង ២៦%) ដឹកតាមរថភ្លើង។ ជើងដឹកជញ្ជូន ២៤ ខ្សែជារៀងរាល់ថ្ងៃ (១២ ខ្សែដឹកចូល/ ១២ ខ្សែដឹកចេញ) មាន ៣0 ទូ (ស្មើរនឹង ៦0 TEUs) ក្នុងមួយជើងផ្តល់សេវាកម្មដឹកជញ្ជូនដោយ SRT។ រយៈពេលដឹកជញ្ជូនពី ICD ទៅកំពង់ផែឡាំឆាបាងតាមរថភ្លើងប្រើពេលអស់ ៣ ម៉ោង ១0 នាទី តាមរថយន្ត ២ ម៉ោងគត់។ ថ្លៃដឹកជញ្ជូនទូទៅតាមរថភ្លើងមានតម្លៃប្រហែល ២.000 បាត/២0’ និង ៣.១00 បាត/៤0’ បើតាមរថយន្តថ្លៃ ៣.១00 បាត/២0’ ឬ ៤0’។ ថ្លៃចំណាយទាំងនេះជាបន្ទុកក្រុមហ៊ុនដឹកខ្សែដឹកជញ្ជូនតាមនាវា។

**តារាង ២.៥-៩: ចំនួនទំនិញលើកដាក់នៅ ICD ឡាត់ក្រាបាង**

(unit:'000 TEUs)

| | | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|
| Import | By Rail | 178 | 195 | 181 | 198 | 149 | 162 |
| | By Truck | 431 | 513 | 598 | 566 | 531 | 530 |
| | By Truck (Other Port) | 29 | 29 | 43 | 37 | 23 | 24 |
| | Sub Total | 638 | 737 | 822 | 800 | 704 | 716 |
| Export | By Rail | 230 | 238 | 239 | 239 | 227 | 238 |
| | By Truck | 420 | 542 | 629 | 675 | 587 | 578 |
| | By Truck (Other Port) | 12 | 14 | 17 | 14 | 15 | 12 |
| | Sub Total | 661 | 794 | 886 | 928 | 830 | 828 |
| Total | | 1,300 | 1,532 | 1,707 | 1,728 | 1,533 | 1,544 |

ប្រភព: សមាគមន៍ភ្នាក់ងារ និង ម្ចាស់នាវាបាកក

### (៤) កំពង់ផែបាងកក

### ១) លក្ខណៈទូទៅ

“កំពង់ផែបាងកក” សំដៅលើចំណតផែថិតនៅតាមដងទន្លេចៅប្រាយ៉ានៅទីក្រុងបាងកក ដែលមានទាំងចំណតផែរបស់ PAT (គឺកំពង់ផែឃ្លងតយ) និងចំណតផែឯកជនមួយចំនួនទៀត។ ទីតាំងចំណតផែសំខាន់ៗមានបង្ហាញក្នុងរូប ២.៥-២៥។ កំពង់ផែបាងកកគឺជាកំពង់ផែមេមួយរបស់ថៃមុនពេលបើកដកំពង់ផែឡាំឆាបាង ដែលបានអភិវឌ្ឍន៍ឡើងដើម្បីបំពេញកង្វះខាតរបស់កំពង់ផែបាងកក ពោលគឺដោយកំពង់ផែបាងកកមានលក្ខណៈតូចចង្អៀត និងជំរៅទឹកនៅជលសីមារ៉ាក់។ បើទោះមុខងារជាច្រកផ្លូវចេញចូលប្រទេសរបស់កំពង់ផែនេះត្រូវដូរទៅឱ្យកំពង់ផែឡាំឆាបាងវិញក៏ដោយ ដោយថិតនៅទីប្រជុំជននៃទីក្រុងកំពង់ផែបាងកកនៅតែមានទំនិញចាក់ធារ និងទំនិញកុងតេន័រលើកដាក់ច្រើនសន្ធឹកសន្ធាប់ដដែល។

កំពង់ផែបាងកកគឺជាកំពង់ផែសំខាន់មួយសម្រាប់កំពង់ផែក្រុងព្រះសីហនុ ដោយកំពង់ផែទាំងពីរនេះមានបណ្តាញខ្សែដឹកជញ្ជូនរួមគ្នា ដូចនេះបើគេអាចពង្រឹងទំនាក់ទំនងជាមួយកំពង់ផែបាងកកឱ្យបានកាន់តែខ្លាំងក្លាថែមទៀត នោះគេរំពឹងថានឹងមានការដឹកជញ្ជូនកើនឡើងចូលមកកំពង់ផែក្រុងព្រះសីហនុ។




ប្រភព: BSAA

**រូប ២.៥-២៥: ទីតាំងចំណតផែនៅកំពង់ផែបាងកក**

### ២) ការគ្រប់គ្រង និងប្រតិបត្តិការផែ

ចំណតផែនីមួយៗនៅកំពង់ផែបាងកកកាន់កាប់ធ្វើប្រតិបត្តិការដោយអង្គភាពខុសៗគ្នា។ កំពង់ផែឃ្លងតយកាន់កាប់ធ្វើប្រតិបត្តិការដោយអាជ្ញាធរផែថៃ (PAT) ចំណែកចំណតផែផ្សេងទៀតកាន់កាប់ធ្វើប្រតិបត្តិការដោយក្រុមហ៊ុនឯកជន។ ឃ្លងនាវាចរណ៍ពីកំពង់ផែទៅសមុទ្រក្រៅថៃទាំងដោយ PAT ។

### ៣) ឋបនីយភណ្ឌ និងគ្រឿងចក្រ

#### ក) ចំណតផែ PAT

ចំណតផែ PAT ឋិតនៅច្រាំងខាងឆ្វេងនៃទន្លេចៅប្រាយ៉ានៅចន្លោះគីឡូម៉ែត្រលេខ ២៦.៥ និងលេខ ២៨.៥ ក្នុងស្រុកឃ្លងតយ។ នៅក្នុងតំបន់ផែ ជំរៅទឹកប្រែប្រួលចន្លោះពី ៨.៥ ទៅ ១១ ម ក្រោម MSL ។ MSL មានកំពស់ ១.៧២ ម លើនូវ៉ូទឹកកម្រិតទាបបំផុត (LLW) ។ ផ្លូវចូលទៅកំពង់ផែចំងាយ ១៨ គម និងឃ្លងនាវាចរណ៍ទទឹង ១៥០ ម។

ចំណតផែនេះមានចំណតនាវាពីរគឺចំណតខាងលិចប្រវែង ១.៦៦០ ម និងខាងកើតប្រវែង ១.៥២៨ ម។ នូវ៉ូទឹកនៅច្រាំងចំណតខាងលិចកំពស់ ១.៨៥ ម លើ MSL នឹងនៅខាងកើតកំពស់ ២.០៦ ម។ ចំណតខាងកើតមានដងយោងធន់ធ្ងន់នៅច្រាំងផែ ១៤ គ្រឿង ចំណែកនៅចំណតខាងលិច នាវាគេមានដងយោងលើកដាក់ផ្ទុកផ្ទេរកុងតេន័រដោយខ្លួនឯង។




ប្រភព: BSAA

**រូប ២.៥-២៦: ទីតាំងចំណតផែ PAT នៅកំពង់ផែបាងកក**

#### ខ) ចំណតផែឯកជន

ក្រៅពីចំណតផែគ្រប់គ្រងធ្វើប្រតិបត្តិការដោយ PAT នៅមានចំណតផែឯកជនបួនទៀតនៅតាមដងទន្លេចៅប្រាយ៉ាដូចជាចំណតផែ BMTP ចំណតផែ BDS ចំណតផែថៃរុងរឿង (TPT) និងចំណតផែកុងតេន័រយូនីថៃ។ ឋបនីយភណ្ឌសំខាន់ៗនៅចំណតផែឯកជនទាំងនេះមានសង្ខេបក្នុងតារាង ២.៥-១០។

**តារាង ២.៥-១០: បរិក្ខារសំខាន់ៗនៅចំណតផែឯកជនក្នុងកំពង់ផែបាងកក**

| Berth | Length (m) | Depth (m) | Shore Cranes | Container Yard Capacity |
|---|---|---|---|---|
| BMTP 1C | 315 | 8.5 | 3 mobile cranes (lift max 100 tons) | 2,500 TEUs |
| BDS No.7 | 150 | 8.5 | 42 tons mobile crane 17 tons mobile crane | 2,200 TEUs |
| TPT | 275 | 8.5 | 2 x 100 tons mobile crane (To be increased for the extended berth) | 9,600 TEUs |
| UTCT 2F | 202 | 8.5 | 3 x 36 tons gantry crane | 3,600 TEUs |

ប្រភព: BSAA, TPT (រៀបចំឡើងវិញដោយក្រុមសិក្សាគម្រោង)

### ៤) ទំនិញឆ្លងកាត់ផែ

ដូចដែលបានបង្ហាញក្នុងរូប ២.៥-២៧ ចំណែងផែកាន់កាប់ដោយរដ្ឋ PAT លើកដាក់កុងតេន័រសរុបបានប្រហែល ៨0% នៅកំពង់ផែបាងកក។ ដោយឡែកនៅចំណតផែឯកជនកុងតេន័រលើកដាក់ក៏មានការកើនឡើងតិចតួចដែរ ដោយចំណតផែទាំងនេះបានបង្កើនសមត្ថភាពលើកដាក់របស់ខ្លួនដូចមានបង្ហាញក្នុងតារាង ២.៥-១១។ ដោយចំណតផែ PAT បានអភិវឌ្ឍន៍ពេញអស់ហើយ PAT មិនមានផែនការបង្កើនសមត្ថភាពចំណតផែរបស់ខ្លួនទៀតទេ។

ដូចនេះ បើទោះមានការអភិវឌ្ឍន៍កំពង់ផែឡាំឆាបាងហើយក៏ដោយ កំពង់ផែបាងកកនៅអាចលើកដាក់កុងតេន័របានច្រើនសន្ធឹក ដែលមានចំនួនកើនឡើងជាបន្តបន្ទាប់ តែអត្រាកំនើនមិនសូវជាច្រើនប៉ុន្មានទេ ដោយសារនៅកំពង់ផែនេះសមត្ថភាពលើកដាក់មានកម្រិត។




ប្រភព: BSAA (រៀបចំឡើងវិញដោយក្រុមសិក្សាគម្រោង)

**រូប ២.៥-២៧: សមាមាត្រចំនួនកុងតេន័រលើកដាក់នៅកំពង់ផែបាងកក**

## តារាង ២.៥-១១: ចំនួនកុងតេន័រឆ្លងកាត់កំពង់ផែបាងកកគិតតាមលំដាប់ពេល

(TEU)

| | | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| PAT Terminal | Inbound | 662,800 | 747,900 | 783,442 | 719,751 | 679,740 |
| | Outbound | 697,935 | 789,707 | 792,122 | 655,417 | 655,063 |
| | Total | 1,360,735 | 1,537,607 | 1,575,564 | 1,375,168 | 1,334,803 |
| Private Terminals | | | | | | |
| BMTP | Inbound | 24,669 | 32,377 | 29,293 | 45,717 | 30,927 |
| | Outbound | 5,848 | 6,273 | 7,365 | 31,233 | 19,619 |
| | Total | 30,517 | 38,650 | 36,658 | 76,950 | 50,546 |
| TPT | Inbound | 83,303 | 83,534 | 86,557 | 118,266 | 103,138 |
| | Outbound | 38,302 | 35,527 | 40,208 | 59,217 | 62,765 |
| | Total | 121,605 | 119,061 | 126,765 | 177,483 | 165,903 |
| Unithai | Inbound | 31,106 | 35,087 | 37,196 | 62,241 | 55,177 |
| | Outbound | 28,658 | 30,763 | 30,765 | 64,365 | 54,511 |
| | Total | 59,764 | 65,850 | 67,961 | 126,606 | 109,688 |
| BOS | Inbound | 14,424 | 15,558 | 17,786 | 14,404 | 11,545 |
| | Outbound | 11,257 | 8,025 | 6,912 | 6,316 | 12,142 |
| | Total | 25,681 | 23,583 | 24,698 | 20,720 | 23,687 |
| Total of Private Terminals | Inbound | 153,502 | 166,556 | 170,832 | 240,628 | 200,787 |
| | Outbound | 84,065 | 80,588 | 85,250 | 161,131 | 149,037 |
| | Total | 237,567 | 247,144 | 256,082 | 401,759 | 349,824 |
| Total of Bangkok Port | Inbound | 816,302 | 914,456 | 954,274 | 960,379 | 880,527 |
| | Outbound | 782,000 | 870,295 | 877,372 | 816,548 | 804,100 |
| | Total | 1,598,302 | 1,784,751 | 1,831,646 | 1,776,927 | 1,684,627 |

ប្រភព: BSAA (រៀបចំឡើងវិញដោយក្រុមសិក្សាគម្រោង)

### ៥) ផែនការអភិវឌ្ឍន៍

PAT បានអនុវត្តគម្រោងខាងក្រោមដើម្បីការពារចំណតផែរបស់ខ្លួនទប់ទល់នឹងទឹកជំនន់ពីទន្លេចៅប្រាយ៉ា:-

- ធ្វើជញ្ជាំងបេតុងការពារទឹកជំនន់កម្រាស់ ១៥ សម កំពស់ +២.៦៥ ម លើនីវ៉ូសមុទ្រ នៅតាមច្រាំងទន្លេ
- សង់ទីជំរាលចាក់កៅស៊ូកំពស់ +២.៤ ម លើនីវ៉ូសមុទ្រធ្វើជាឃឿនការពារទីពីរ
  សង់ជញ្ជាំងដកម្រាស់ពីរជាន់ ដើម្បីទប់ទឹកកុំឱ្យហូរខ្លាំងបុកចូលទៅអាគារ OB និងទីជំរាលចាក់កៅស៊ូកំពស់ ១៥ សម នៅមុខនាយកដ្ឋានពន្លត់អគ្គីភ័យដើម្បីបង្វែរមុខទឹក។

PAT ក៏គ្រោងអភិវឌ្ឍន៍ដីនៅជុំវិញចំណតផែរបស់ខ្លួន ដែលភាគច្រើនប្រើប្រាស់ដោយឧស្សាហកម្មពស្តុភារបច្ចុប្បន្ន និងដើម្បីសាងសង់ជាមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ។ PAT កំពង់ផែរងចាំការអនុម័ត្រលើផែនការអភិវឌ្ឍន៍នេះពីរដ្ឋាភិបាល។

### (៥) កំពង់ផែស៊ុងក្លា

កំពង់ផែស៊ុងក្លាឋិតនៅខេត្តស៊ុងក្លាភាគខាងត្បូងប្រទេសថៃ នៅជាប់នឹងឈូងសមុទ្រថៃ ចំងាយ ៩៥០ គម ពីទីក្រុងបាងកក និង ៧០ គម ពីព្រំដែនម៉ាឡេស៊ី។




ប្រភព: Google ក្រុមសិក្សាគម្រោង

**រូប ២.៥-២៨: ទីតាំងកំពង់ផែស៊ុងក្លា**

កំពង់ផែនេះមានចំណតផែកុងតេន័រ/ចំណតផែទំនិញទូទៅ (ចំណតផែ CTIC) កាន់កាប់ធ្វើប្រតិបត្តិការដោយក្រុមហ៊ុនកំពង់ផែចៅប្រាយ៉ាអន្តរជាតិ ដែលជាប្រតិបត្តិករឯកជន និងចំណតផែប្រេងមួយចំនួនកាន់កាប់ដោយអាជ្ញាធរប្រេងថៃ (PTT)។ កំពង់ផែសាងសង់នៅឆ្នាំ ១៩៨៦ ក្រោមកម្ចី ADB។ CTIC ជាសម្បទានិកចំណតផែកុងតេន័រ/ចំណតផែទំនិញទូទៅតាំងពីឆ្នាំ ១៩៨៨។

កំពង់ផែថិតក្រោមរដ្ឋបាលនាយកដ្ឋានសមុទ្រចំណុះក្រសួងដឹកជញ្ជូន។ រូប ២.៥-២៩ និង តារាង ២.៥-១២ បង្ហាញពីឋបនីយភណ្ឌផែចំណតផែ CTIC។




ប្រភព: ក្រុមហ៊ុនកំពង់ផែចៅផាយ៉ាអន្តរជាតិ

**រូប ២.៥-២៩: គម្រោងប្លង់ចំណតផែ CTIC**

**តារាង ២.៥-១២: បំបនីយភណ្ឌចំណតផែ**

| | | |
|---|---|---|
| Berths | | |
| Ship Berths | | 3 |
| Total Berth Length | (m.) | 510 |
| Design Depth | (m.) | 9.0 |
| Maximum Vessel LOA | (m.) | 173 |
| Area & Capacity | | |
| Total Area | (ha) | 10 |
| Container Yard: | (sq.m.) | 50,000 |
| Transit Shed: | (sq.m.) | 6,726 |
| Break Bulk Cargo Working | (sq.m.) | 9,300 |
| Container Capacity | (TEU/year) | 160,000 |
| Conventional Capacity | (Tons/year | 600,000 |
| Reefer Points | | 236 |
| Equipments | | |
| Quay mobile cranes (16 tons) | | 2 |
| Forklifts (3 - 3.5 tons) | | 12 |
| Forklifts (16 tons) | | 8 |
| Forklifts (40 tons) | | 6 |
| Tow Tractors (40 tons) | | 15 |
| Semi-Trailers (40 tons) | | 12 |
| Weigh Bridge (80 Tons) | | 2 |

ប្រភព: ក្រុមហ៊ុនកំពង់ផែចៅប្រាយ៉ាងអន្តរជាតិ

ទំនិញនាំចេញសំខាន់ៗមានដូចជា:-ជ័រកៅស៊ូ អាហារសមុទ្រក្លាសេ អាហារកំប៉ុង និងគ្រឿងសង្ហារឹម ចំណែកទំនិញនាំចូលវិញមានដូចជា:-ត្រីធ្យូណាក្លាសេ និងគ្រឿងចក្រ។ តារាង ២.៥-១៣ បង្ហាញពីបរិមាណទំនិញកំពង់ផែលើកដាក់បាននៅប៉ុន្មានឆ្នាំថ្មីៗនេះ។

**តារាង ២.៥-១៣: បរិមាណទំនិញលើកដាក់បាននៅកំពង់ផែស៊ុងក្លា**

| | | | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|
| Conventional ('000 tons) | Import | | 269 | 227 | 206 | 239 |
| | Export | | 422 | 406 | 428 | 50 |
| | Sub Total | | 691 | 633 | 634 | 289 |
| Container ('000 tons) | Import | | 205 | 216 | 230 | 244 |
| | Export | | 934 | 967 | 958 | 874 |
| | Sub Total | | 1,139 | 1,183 | 1,188 | 1,118 |
| Total ('000 tons) | Import | | 474 | 443 | 436 | 483 |
| | Export | | 1,357 | 1,373 | 1,386 | 924 |
| | Total | | 1,830 | 1,816 | 1,822 | 1,407 |
| Container ('000TEUs) | Import | Laden | 16 | 16 | 16 | 17 |
| | | Empty | 53 | 54 | 53 | 45 |
| | | Sub Total | 70 | 70 | 68 | 62 |
| | Export | Laden | 66 | 68 | 69 | 64 |
| | | Empty | 3 | 2 | 1 | 2 |
| | | Sub Total | 69 | 70 | 70 | 65 |
| | Total | Laden | 82 | 84 | 84 | 81 |
| | | Empty | 56 | 56 | 54 | 47 |
| | | Total | 139 | 140 | 138 | 128 |

ប្រភព: ក្រុមហ៊ុនកំពង់ផែចៅផាយ៉ាអន្តរជាតិ

ផែនការពង្រីកបន្ថែមទំនងជាបានសិក្សារួចហើយ ក្នុងផែនការនោះរួមមានការសាងសង់ចំណតកុងតេន័រទី ៤ និង ទី ៥ បើទោះនាយកដ្ឋានសមុទ្រមិនបានផ្តល់ការឯកភាព ហើយគម្រោងនេះក៏មិនបានអនុវត្តយ៉ាងណាក៏ដោយ ។

**(៦) កំពង់ផែឃួនថាន**

**១) លក្ខណៈទូទៅ**

កំពង់ផែឃួនថានគឺជាកំពង់ផែពាណិជ្ជកម្មមួយថិតនៅចំងាយ ២៥ គម ពីទីក្រុងឃួនថាន ដែលជារដ្ឋធានីផាហាងជាប់សមុទ្រចិនខាងត្បូង ។ កំពង់ផែឃួនថានគឺជាច្រកផ្លូវចេញចូលសំខាន់សម្រាប់ការធ្វើជំនួញនៅតំបន់អាស៊ីប៉ាស៊ីហ្វិក និងតំបន់សេដ្ឋកិច្ចឆ្នេរសមុទ្រខាងកើតនៃឧបទ្វីបម៉ាឡេស៊ី ។

**២) ការគ្រប់គ្រង និងប្រតិបត្តិការផែ**

ការគ្រប់គ្រងកំពង់ផែឃួនថានត្រូវបានធ្វើឯកជនភាវូបនីយកម្មនៅឆ្នាំ ១៩៩៨។ ក្រុមហ៊ុន Kauntan Port Consortium Sdn Bhd (KPC) ដែលជាសាខាក្រុមហ៊ុនកាប់កាន់ទាំងស្រុងរបស់ក្រុមហ៊ុន Road Builder Holdings Berhad គឺជាក្រុមហ៊ុនសម្បទានិក និងជាប្រតិបត្តិករកំពង់ផែឃួនថាន ផ្តល់សេវាកម្មលើកដាក់ទំនិញផង និងសេវាកម្មនាវាចរណ៍ផងដែរ ។

**៣) ឋបនីយភណ្ឌ និងគ្រឿងចក្រ**

ឋបនីយភណ្ឌផែសំខាន់ៗនៅក្នុងកំពង់ផែមានបង្ហាញដោយសង្ខេបក្នុងតារាង ២.៥-១៤ ចំណែកគម្រោងប្លង់ផែមានបង្ហាញក្នុងរូប ២.៥-៣០ ។ ចំណតផែកុងតេន័រមានដាក់ដងយោងធន់ធ្ងន់នៅច្រាំងផែ និង RTGs ជាច្រើនគ្រឿង ។

**តារាង ២.៥-១៤: ឋបនីយភណ្ឌសំខាន់ៗនៅកំពង់ផែឃួនថាន**

| | Number | Length (m) | Draft (m) |
|---|---|---|---|
| Liquid Bulk Berth | | | |
| Palm Oil Berth | 3 | 630 | 8 - 11.2 |
| Mineral Oil Berth | 1 | 150 | 8.0 |
| Liquid Chemical Berth | 3 | 720 | 11.2 |
| Multipurpose Berth | 8 | 1,073 | 8 - 11.2 |
| Container Berth | 3 | 600 | 11.2 |

ប្រភព: Kuantan Port Consortium (រៀបចំឡើងវិញដោយក្រុមសិក្សាគម្រោង)




ប្រភព: Kuantan Port Consortium

**រូប ២.៥-៣០: គម្រោងប្លង់បឋមនីយកណ្ឌនៅកំពង់ផែឃួនថាន**

### ៤) ចរាចរទំនិញ និងចំនួននាវាចេញចូលផែ

បរិមាណទំនិញ និងកុងតេន័រលើកដាក់សរុបនៅកំពង់ផែ និងចំនួននាវាចេញចូលផែសរុបតាមលំដាប់ពេលមានបង្ហាញក្នុង តារាង ២.៥-១៥។ បើប្រៀបធៀបជាមួយទំនិញ បរិមាណកុងតេន័រលើកដាក់បាននៅកំពង់ផែមានចំនួនតិចជាងច្រើន។

**រូប ២.៥-១៥: បរិមាណទំនិញលើកដាក់នៅផែ និងចំនួននាវាចេញចូលផែឃួនថាន**

| Year | Total Cargo Handling Volume (1,000 FT) | Container Handling Volume (TEUs) | Vessels Call |
|---|---|---|---|
| 1998 | 5,500 | 50,989 | 1,410 |
| 1999 | 5,510 | 56,056 | 1,516 |
| 2000 | 6,027 | 62,783 | 1,677 |
| 2001 | 7,532 | 76,339 | 1,855 |
| 2002 | 8,999 | 91,524 | 2,067 |
| 2003 | 9,804 | 108,108 | 2,280 |
| 2004 | 9,699 | 122,745 | 2,382 |
| 2005 | 9,411 | 119,167 | 2,195 |
| 2006 | 10,673 | 124,834 | 2,324 |
| 2007 | 10,065 | 127,600 | 2,375 |
| 2008 | 9,402 | 127,061 | 2,315 |
| 2009 | 10,273 | 132,250 | 2,447 |
| 2010 | 12,079 | 142,080 | 2,405 |

ប្រភព: Kuantan Port Consortium (រៀបចំឡើងវិញដោយក្រុមសិក្សាគម្រោង)

### ៥) ផែនការអភិវឌ្ឍន៍

គម្រោងអភិវឌ្ឍន៍កំពង់ផែរបស់ក្រុមហ៊ុន Kuantan Port Consortium ដូចមានបង្ហាញក្នុងរូប ២.៥-៣១។ ការអភិវឌ្ឍន៍ដំណាក់កាលទី ១ គឺសាងសង់ចំណតផែកុងតេន័រប្រវែង ១.០០០ ម អាចឱ្យនាវាដឹកកុងតេន័រធុនធំមធ្យមចូលចតបាន។ នៅដំណាក់កាលទី ២ គេគ្រោងនឹងអភិវឌ្ឍន៍ចំណតផែកុងតេន័រប្រវែង ១.០០០ ម មួយទៀត។ គម្រោងអភិវឌ្ឍន៍សំខាន់ៗ មានដូចតទៅ:-

- បង្កើនជំរៅទឹកនៅកំពង់ផែឃួនថានពី ១២.២ ម ទៅ ១៨.០ ម
- បង្កើនជំរៅស៊ីទឹកអតិបរមាសម្រាប់នាវាពី ១១.២ ម ទៅ ១៦.០ ម
- ពង្រីកជលសីមាសម្រាប់ឱ្យនាវាបត់ចុះឡើងប្រវែងពី ៥០០ ម ទៅ ៨០០ ម
- បង្កើនវបនីយភណ្ឌលើកដាក់ទំនិញ
- បង្កើនវបនីយភណ្ឌលើកដាក់សម្រាប់នាវា




ប្រភព: Kuantan Port Consortium

**រូប ២.៥-៣១: ផែនការអភិវឌ្ឍន៍កំពង់ផែឃួនថាន**